ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA

អង្គការពាណិជ្ជកម្មពិភពលោក
WORLD TRADE ORGANIZATION

# កម្ពុជា និង
# អង្គការពាណិជ្ជកម្មពិភពលោក
# Cambodia and
# the World Trade Organization


បទឧទ្ទេសនាមរបស់ ឯកឧត្តម ចម ប្រសិទ្ធ
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
និងជាប្រធានក្រុមចរចាកម្ពុជាក្នុងការសុំចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក

**By H.E. Cham Prasidh**
**Senior Minister, Minister of Commerce**
**and Chief Negotiator of Cambodia's Accession to WTO**



ភ្នំពេញ ខែ សីហា ឆ្នាំ ២០០៤
Phnom Penh, August 2004

# កម្ពុជា និង អង្គការពាណិជ្ជកម្មពិភពលោក

# Cambodia and the World Trade Organization



បទឧទ្ទេសនាមរបស់ ឯកឧត្តម ចម ប្រសិទ្ធ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

និងជាប្រធានក្រុមចរចាកម្ពុជាក្នុងការសុំចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក

By H.E. Cham Prasidh

Senior Minister, Minister of Commerce

and Chief Negotiator of Cambodia's Accession to WTO

ភ្នំពេញ ខែ កក្កដា ឆ្នាំ ២០០៤

Phnom Penh, July 2004

# កម្ពុជា និង អង្គការពាណិជ្ជកម្មពិភពលោក

បទឧទ្ទេសនាមរបស់

ឯកឧត្តម ចម ប្រសិទ្ធ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

និងជាប្រធានក្រុមចរចាកម្ពុជាក្នុងការសុំចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក

អង្គការពាណិជ្ជកម្មពិភពលោក ធនាគារពិភពលោក និងអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ ជាអង្គការ អន្តរជាតិ បីសំខាន់ ដែលមានតួនាទីចាត់ចែងរៀបចំសេដ្ឋកិច្ចពិភពលោក ។ រហូតមកដល់ពេលនេះ ក្នុងចំណោមអង្គការទាំងបីមានតែអង្គការពាណិជ្ជកម្មពិភពលោកមួយប៉ុណ្ណោះដែលកម្ពុជាមិនទាន់បានចូលជាសមាជិក ។ នៅឯកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីនៃប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក លើកទី៥ ដែលបានប្រារព្ធធ្វើនៅទីក្រុង កាន់គូន ប្រទេសម៉ិចស៊ិច កាលពីថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០០៣ កម្ពុជាត្រូវបានអនុញ្ញាតិអោយចូលជាសមាជិកនៃអង្គការដ៏សំខាន់នេះដោយផ្អែកតាមលក្ខខ័ណ្ឌ និងការសន្យាធ្វើ ដែលមានចែងក្នុងពិធីសារនៃការចូលជាសមាជិក ដែលបានព្រមព្រៀងរវាងកម្ពុជា និងសមាជិកដ៏ទៃទៀតនៃអង្គការនេះ ។ ពិធីសារនេះ គឺជាលទ្ធផលលំអិតនៃការចរចាររវាងកម្ពុជា និង សមាជិក នានា ដែលចាប់ផ្តើមធ្វើជាលើកដំបូងកាលពីពាក់កណ្តាលឆ្នាំ ១៩៩៩ គឺនៅពេលដែលកម្ពុជាបានបញ្ជូនអនុស្សរណៈស្តីពីរបបពាណិជ្ជកម្មក្រៅប្រទេសរបស់ខ្លួនទៅអង្គការពាណិជ្ជកម្មពិភពលោក ។ ការផ្តល់សច្ចាប័នលើពិធីសារនេះ គឺជាបញ្ហាដំបូង និងសំខាន់បំផុត ដែលរដ្ឋសភាជាតិអណត្តិថ្មីត្រូវធ្វើនៅពេល ដែលរដ្ឋសភាជាតិអាចកោះប្រជុំបាន ។ កម្ពុជានឹងក្លាយជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ក្នុងរយៈពេល ៣០ ថ្ងៃបន្ទាប់ពីបានជូនដំណឹងទៅលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោកថាសភាជាតិបានផ្តល់សច្ចាប័នលើពិធីសារនេះរួចហើយ ។

- តើមានអ្វីខ្លះចែងក្នុងពិធីសារនេះ ?
- តើពិធីសារនេះ នឹងមានឥទ្ធិពលបែបណាមកលើប្រទេសកម្ពុជា ?
- តើអ្វីទៅជាសារៈសំខាន់ចំពោះកម្ពុជា ក្នុងការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ?

# អង្គការពាណិជ្ជកម្មពិភពលោក

អង្គការពាណិជ្ជកម្មពិភពលោក មានសមាជិកទាំងអស់ចំនួន ១៤៧ ប្រទេស ដែលរួមទាំងបណ្ដាប្រទេស ដែលមានកំលាំងសេដ្ឋកិច្ចធំបំផុតក្នុងពិភពលោក លើកលែងតែប្រទេសរុស្ស៊ី ។ បណ្ដាប្រទេសជាសមាជិកអាស៊ានទាំងអស់ សុទ្ធតែជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកលើកលែងតែ សាធារណៈរដ្ឋប្រជាមានិត ប្រជាធិបតេយ្យឡាវ និង សាធារណៈរដ្ឋសង្គមនិយមវៀតណាម ។

## <u>អង្គការពាណិជ្ជកម្មពិភពលោកមានតួនាទីសំខាន់បី</u>

តួនាទី ទី១គឺបង្កើតអោយមានវិធានពាណិជ្ជកម្ម សំរាប់គ្រប់គ្រងការធ្វើពាណិជ្ជកម្មអន្តរជាតិនៃពាណិជ្ជកម្មលើទំនិញនិង ពាណិជ្ជកម្មលើសេវាកម្ម ។ វិធាននេះបានបញ្ចូលនូវបញ្ហាជាច្រើនដែលទាក់ទងទៅនឹងការធ្វើពាណិជ្ជកម្ម រឺបញ្ហាដែលមានឥទ្ធិពលជាដុំកំភួនដល់ការធ្វើពាណិជ្ជកម្ម ។ ឧទាហរណ៍ វិធានខ្លះបានកំណត់យ៉ាងច្បាស់លាស់អំពីរបៀបវាយតំលៃលើទំនិញនាំចូល ដែលត្រូវអនុវត្តដោយមន្ត្រីគយ ដើម្បីឈានដល់ការយកពន្ធលើការនាំចូល រឺ វិធានដែលកំណត់ អំពីរបៀប ដែលត្រូវអនុវត្តលើស្តង់ដាសុវត្ថិភាព និង លទ្ធភាពប៉ះពាល់ដល់សុខភាពនៃទំនិញនាំចូល ការផ្តល់ការការពារចំពោះកម្មសិទ្ធបញ្ញា និងពីរបៀបរៀបចំធ្វើពាណិជ្ជកម្មសេរីរបៀបណា។

វិធានទាំងនេះមានលក្ខណៈលំអិត និងស្មុគស្មាញ ហើយត្រូវបានចែងនៅក្នុងកិច្ចព្រមព្រៀងចំនួន ១៨ ដែលមានជាង ៣០០ទំព័រ។

តួនាទី ទី២ គឺផ្តល់នូវមធ្យោបាយសំរាប់ដោះស្រាយជំលោះពាណិជ្ជកម្ម រវាងប្រទេសជាសមាជិក ដែលកើត ចេញពីការមិនគោរពកិច្ចព្រមព្រៀង ។ ដោយសារភាពស្មុគស្មាញនៃកិច្ចព្រមព្រៀង ពេលខ្លះមានការមិនឯកភាពគ្នា លើការបកស្រាយវិធាននានា រវាងប្រទេសជាសមាជិក។ យន្តការដោះស្រាយជំលោះ នៃអង្គការពាណិជ្ជកម្មពិភពលោក ផ្តល់នូវរបៀបដោះស្រាយ ជំលោះដល់សមាជិកនានា ក្នុងករណីដែលមធ្យោបាយផ្សេងៗទៀតមិនអាចទទួលយកបាន ពីភាគីជម្លោះ ហើយក្រុមឯកទេសដោះស្រាយជំលោះ នឹងកំណត់យកវិធានមួយសំរាប់ ដោះស្រាយ ។ យន្តការនេះមានសារៈសំខាន់បំផុត ជាពិសេសសំរាប់ប្រទេសតូចតាច ដូចជា ប្រទេសកម្ពុជា ។ នោះគឺដោយសារយន្តការដោះស្រាយជំលោះនេះបង្កលក្ខណៈអោយជំលោះ ពាណិជ្ជកម្មទ្វេភាគីជាមួយប្រទេសធំ ត្រូវបានដោះស្រាយដោយផ្អែកលើវិធានច្បាប់ជាមូលដ្ឋាន ជាជាងដោះស្រាយដោយផ្អែក តែលើការចរចាជាមួយប្រទេស ដែលមានឥទ្ធិពលសេដ្ឋកិច្ច និងពាណិជ្ជកម្មធំជាង ។

តួនាទី ទី៣ របស់អង្គការពាណិជ្ជកម្មពិភពលោក គឺត្រូវបានប្រើជាវេទិការសំរាប់ការចរចា ដើម្បីធ្វើអោយរីកចំរើនដល់ការធ្វើសេរីភាវូបនីយកម្ម នៃពាណិជ្ជកម្មអន្តរជាតិ ។ ការចរចា ត្រូវបានប្រព្រឹត្តទៅតាមរយៈវេទិការចរចានានា ដែលសមាជិកទាំងអស់ចរចាកាត់បន្ថយពន្ធ នាំចូលផលិតផលទំនិញ ហើយចំពោះការចរចាបើកទីផ្សារលើវិស័យសេវាកម្ម ត្រូវបានប្រព្រឹត្ត ទៅនៅឯកិច្ចចរចា Uruguay round ។

ពុំមានសេចក្តីចែងជាផ្លូវការអំពីលក្ខខណ្ឌតំរូវនានា ដែលប្រទេសមួយត្រូវធ្វើ ដើម្បីបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកទេ។ នៅក្នុងកិច្ចព្រមព្រៀងបង្កើត អង្គការពាណិជ្ជកម្មពិភពលោកគ្រាន់តែចែងយ៉ាងធម្មតាថា ប្រទេសមិនមែនជាសមាជិកមួយ អាចក្លាយជាសមាជិកបានដោយផ្អែកលើលក្ខខណ្ឌ ដែលនឹងត្រូវព្រមព្រៀងរវាងប្រទេសនោះ ជាមួយសមាជិកដទៃទៀតនៃអង្គការពាណិជ្ជកម្មពិភពលោក ។ ទោះបីយ៉ាងណាក៏ដោយការ

អនុវត្តន៍ជាក់ស្តែងមួយចំនួនក្នុងពេលកន្លងមកបានផ្តល់នូវគំរូសមស្របមួយ ចំពោះអ្វីដែលប្រទេសសុំចូលជាសមាជិកត្រូវធ្វើ ។ ជាទូទៅ ប្រទេសសុំចូលជាសមាជិកត្រូវធ្វើការសន្យាធ្វើលើវិស័យមួយចំនួនទាក់ទងទៅនឹងតួនាទីខាងលើគឺៈ

- ត្រូវចរចាជាមួយប្រទេសជាសមាជិកនានាដើម្បី ចងអត្រាពន្ធលើទំនិញនាំចូល រឺកំណត់អត្រាពន្ធខ្ពស់បំផុត ដែលត្រូវអនុវត្តលើទំនិញនាំចូល ។
- ត្រូវចរចាជាមួយប្រទេសជាសមាជិកនានា លើលក្ខខណ្ឌនៃការបើកទីផ្សារវិស័យសេវាកម្ម ដែលអនុញ្ញាតអោយអ្នកផ្តល់សេវាបរទេសមកផ្តល់សេវាកម្មលើទីផ្សារក្នុងស្រុករបស់ខ្លួន ។
- ត្រូវព្រមព្រៀងលើកំរិតនៃការឧបត្ថម្ភធនរបស់រដ្ឋ ចំពោះវិស័យកសិកម្មដែលមានឥទ្ធិពលដល់ពាណិជ្ជកម្មអន្តរជាតិ ។
- ត្រូវធ្វើយ៉ាងណាអោយច្បាប់ និងបទប្បញ្ញត្តិនានា ដែលគ្រប់គ្រងការធ្វើពាណិជ្ជកម្មអន្តរជាតិស្របជាមួយ នឹង វិធានរបស់អង្គការពាណិជ្ជកម្មពិភពលោកនៅមុនពេលចូលជាសមាជិក ។

ទោះបីយ៉ាងណាក៏ដោយ ជាការកត់សំគាល់គឺ ប្រទេសជាសមាជិកនានាបានផ្តល់នូវការអនុគ្រោះដែលអាចទទួលយកបានដោយប្រទេសក្រីក្រ ដែលសុំចូលជាសមាជិកលើវិស័យទាំងបួននេះ ។ នៅក្នុងសេចក្តីសំរេចរបស់អគ្គក្រុមប្រឹក្សា នៃអង្គការពាណិជ្ជកម្មពិភពលោកដែលបានធ្វើកាលពីខែ ធ្នូ ឆ្នាំ ២០០២ បញ្ជាក់ថា ប្រទេសជាសមាជិកបានព្រមព្រៀងគោរពតាមលក្ខខ័ណ្ឌកំរិតមួយចំនួនក្នុងការចរចាជាមួយប្រទេសក្រីក្រដែលស្វែងសុំចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។ ជាពិសេស សមាជិកនានាបានព្រមព្រៀងថាៈ

១- នឹងមិនតំរូវអោយប្រទេសក្រីក្រកាត់បន្ថយពន្ធនាំចូលជាគំហុគទេ ហើយតំរូវអោយធ្វើសម្បទានបើកទីផ្សារលើវិស័យមួយចំនួនប៉ុណ្ណោះ គឺពាណិជ្ជកម្មលើទំនិញ ពាណិជ្ជកម្មលើសេវាកម្ម

២- អនុញ្ញាត្តិអោយប្រទេសក្រីក្របានចូលជាសមាជិក មុនពេលដែលច្បាប់ និងបទប្បញ្ញត្តិទាំងឡាយរបស់គេ ស្របទាំងស្រុងទៅនឹងវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក ដោយផ្អែកតែទៅលើផែនការដែលបានដាក់ស្នើ ក្នុងការធ្វើអោយច្បាប់បញ្ញត្តិរបស់ខ្លួនស្របទៅនឹងវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក ក្នុងរយៈពេលមួយច្បាស់លាស់បន្ទាប់ពីថ្ងៃបានចូលជាសមាជិក ហើយប្តេជ្ញាបំពេញអោយបានជោគជ័យនូវផែនការនោះ ប៉ុណ្ណោះ ។

ដោយសារកម្ពុជាជាប្រទេសក្រីក្រ យើងសង្ឃឹមថា កម្ពុជាអាចទទួលបានផលប្រយោជន៍ពីការអនុគ្រោះ ដែលមាននៅក្នុងសេចក្តីសំរេចនេះ ។

## របៀបចរចាចូលជាសមាជិក របស់កម្ពុជា

### <u>ពាណិជ្ជកម្ម ការអភិវឌ្ឍន៍ និងការបង្កើតការងារធ្វើ</u>

ចាប់តាំងពីដំបូងមកកម្ពុជាយល់ឃើញថា ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនឹងមាននាទីយ៉ាងសំខាន់ ក្នុងការបង្កើតល្បឿនអភិវឌ្ឍន៍របស់ខ្លួន ។ ដើម្បីទាញយកប្រយោជន៍អោយបានច្រើនបំផុត និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានអោយនៅទាបបំផុត កម្ពុជាត្រូវរៀបចំយុទ្ធសាស្ត្រ នៃការចរចាមួយ ដែលសមស្របបំផុតសំរាប់ប្រយោជន៍កម្ពុជា ដែលយុទ្ធសាស្ត្រនេះនឹងផ្តល់នូវលទ្ធផល ដែលកម្ពុជាចង់បាន ។ ក្នុងការបង្កើតយុទ្ធសាស្ត្រនេះឡើង យើងបានចាប់ផ្តើមពីមូលដ្ឋានជាក់ស្តែង នៃស្ថានភាពបច្ចុប្បន្នរបស់កម្ពុជា ។

កម្ពុជាជាប្រទេសតូច មានប្រជាជនតិច ប្រជាជនមួយភាគធំជាជនក្រីក្រ និងមានកំណើនប្រជាជនខ្ពស់ ។ ចំនួនយុវជនដែលត្រូវការការងារធ្វើមានកំណើនខ្ពស់ ហើយកំណើននេះនឹងកើនឡើងថែមទៀតយ៉ាងឆាប់រហ័សក្នុងបណ្តាឆ្នាំខាងមុខ ។ ដូច្នេះការបង្កើតការងារថ្មីៗថែមទៀតអោយបានឆាប់ គឺជាបញ្ហាប្រឈម ដែលកម្ពុជាកំពុងជួបប្រទះ ។ ដោយសារកំលាំងទិញនៅក្នុងស្រុកមានកំរិតទាបពេក ការបង្កើតការងារថ្មីៗទៀតគឺអាស្រ័យ តែលើការផលិតសំរាប់ផ្គត់ផ្គង់លើទីផ្សារធំៗ នៅបរទេសតែប៉ុណ្ណោះ ។ ដូច្នេះកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍របស់កម្ពុជានៅពេលអនាគត គឺជាការអភិវឌ្ឍន៍ពីក្នុងទៅក្រៅ ដែលការនាំចេញមាននាទីយ៉ាងសំខាន់ក្នុងការបង្កើតការងារថ្មី និងកាត់បន្ថយភាពក្រីក្រ ។

បទពិសោធន៍របស់កម្ពុជា លើឧស្សាហកម្មកាត់ដេរសំលៀកបំពាក់បានបង្ហាញច្បាស់ពីតួនាទីនៃការនាំចេញក្នុងការបង្កើតការងារថ្មីយ៉ាងឆាប់រហ័យ និងការកាត់បន្ថយភាពក្រីក្រ ។ បច្ចុប្បន្នឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ស្រូបយកកំលាំងពលកម្មចំនួនប្រមាណ ២៤០ ០០០ នាក់ ហើយដែលចំនួនពាក់កណ្តាលនៃចំនួនការងារនេះត្រូវបានបង្កើតឡើងក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ដែលយើងអាចចាត់ទុកថាឧស្សាហកម្មកាត់ដេរគឺជាប្រភពផ្តល់ការងារធំជាងគេតែមួយគត់ក្នុងរយៈពេលនេះ ។ កម្មករភាគច្រើនមានប្រភពចេញពីគ្រួសារ ដែលមានប្រាក់ចំណូលទាប ហើយប្រាក់ចំណូលរបស់ពួកគេជាធម្មតាផ្គត់ផ្គង់ទៅអោយគ្រួសារ នៅឯជនបទ ។

ស្ថានភាពជាក់ស្តែងទី២ នៅកម្ពុជាបច្ចុប្បន្នៈ គឺថាការបង្កើនបរិមាណទំនិញនាំចេញ និងការបង្កើតការងារថ្មី អាចកើតមានឡើងបាន លុះត្រាតែមានកំណើនរហ័សនៃការធ្វើវិនិយោគពីបរទេស ។ ពីព្រោះសញ្ជ័យធន បច្ចេកទេសជំនាញ និងបច្ចេកវិទ្យា ពេលខ្លះមិនអាចរកបានទេនៅកម្ពុជា ហើយក្រុមហ៊ុនវិនិយោគបរទេស មាននាទីយ៉ាងសំខាន់ក្នុងការពង្រីកវិស័យនាំចេញ ដោយហេតុថា ក្រុមហ៊ុនបរទេសដឹងពីទីផ្សារសំរាប់នាំចេញ មានបច្ចេកវិទ្យា បទពិសោធន៍នៃការគ្រប់គ្រង បណ្តាញម៉ាខេទិញ ដែលជាកត្តាធ្វើអោយការរកស៊ីទទួលបានប្រាក់ចំណេញ ។

បទពិសោធន៍លើឧស្សាហកម្មកាត់ដេរសំលៀកបំពាក់របស់កម្ពុជា បានបង្ហាញច្បាស់ពីរបៀបដែលការវិនិយោគផ្ទាល់ពីបរទេស អាចត្រូវបានប្រើប្រាស់ក្នុងការពង្រីកការនាំចេញ ។ ការនាំចេញសំលៀកបំពាក់បានកើនឡើងពី ២៦ លានដុល្លា ក្នុងឆ្នាំ ១៩៩៥ ទៅ ៦៥០ លានដុល្លា នៅឆ្នាំ ១៩៩៩ និងច្រើនជាង ១ ៣០០ លានដុល្លា ក្នុងឆ្នាំ ២០០៣ ។ ចំណេះដឹងរបស់សហគ្រាសវិនិយោគបរទេសអំពីទីផ្សារ និងតំរូវការចាំបាច់របស់ទីផ្សារក្រៅប្រទេស គឺជាកត្តាយ៉ាងសំខាន់ក្នុងការពង្រីកការនាំចេញនេះ ។

ទោះបីជាយ៉ាងណាក៏ដោយ ទស្សនៈខាងលើ អំពីការនាំចេញ និង ការវិនិយោគផ្ទាល់ពីបរទេស មិនត្រូវមិនគិតដល់នាទីសំខាន់របស់សហគ្រាសធុនតូច និងធុនមធ្យមក្នុងការអភិវឌ្ឍន៍នៅកម្ពុជាដែរ ។ សហគ្រាសទាំងនេះផលិត ហើយផ្គត់ផ្គង់ទីផ្សារក្នុងស្រុក ហើយក៏រួមចំណែកក្នុងការផ្តល់ការងារធ្វើនៅកម្ពុជា ទោះបីមានកំណើនទាបក៏ដោយ ហើយក៏ជាមូលដ្ឋានសំខាន់ក្នុងការបង្កើតអោយមានសហគ្រិនល្អនៅកម្ពុជា ។

ស្ថានភាពជាក់ស្តែងជាមូលដ្ឋានទីពានៅកម្ពុជាគឺ សង្គមជនបទ និងសេដ្ឋកិច្ច ដែលប្រជាជនភាគច្រើន ពឹងពាក់ដោយផ្ទាល់រឺប្រយោលលើវិស័យកសិកម្ម ។ កម្ពុជាជាប្រទេសដែលមានសក្តានុពលក្នុងការប្រកួតប្រជែងក្នុងវិស័យកសិកម្ម ប៉ុន្តែនៅមានការងារជាច្រើនទៀត ត្រូវធ្វើដើម្បីអោយគេអាចមើលឃើញនូវសក្តានុពល នៃការប្រកួតប្រជែងនេះ ។ ដើម្បីសំរេចបានដូចនេះ តំរូវអោយមានការធ្វើវិនិយោគច្រើនថែមទៀតលើការកសាងហេដ្ឋារចនាសម្ព័ន្ធជនបទក្នុងវិស័យកសិកម្ម បង្កើនជំនាញក្នុងការផលិត និងជំរុញការកែច្នៃម្ហូបអាហារដូចជា ម៉ាស៊ីនកិនស្រូវ និងការលើកកំពស់គុណភាពអង្ករអោយឆ្លើយតបបានទៅនឹងស្តង់ដារអន្តរជាតិ ។ ដូច្នេះនៅទីនេះ កម្មវិធីរបស់រដ្ឋាភិបាល សហគមន៍អ្នកផ្តល់ជំនួយ និងការធ្វើវិនិយោគពីបរទេសមាននាទីយ៉ាងសំខាន់ក្នុងការបំពេញការងារនេះអោយបានជោគជ័យ ។ ការអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជា គឺជាដំណើរវែងឆ្ងាយ និង ស្មុគ្រស្មាញមួយ ដែលតំរូវអោយមានការគាំទ្រពី

នយោបាយពាណិជ្ជកម្ម ដែលផ្តល់ការការពារសមស្របដល់ កសិករនិងផលិតករក្នុងស្រុក ពីការនាំចូលផលិតផលកសិកម្ម ហើយធានាអោយបានថា ផលិតផលកសិកម្មរបស់កម្ពុជាអាច ប្រកួតប្រជែងបាននៅលើទីផ្សារក្រៅប្រទេស ។

ក្រៅពីស្ថានភាពជាក់ស្តែងជាមូលដ្ឋានខាងលើស្ថានភាពជាក់ស្តែង នៃរបបពាណិជ្ជកម្ម ក្រៅប្រទេសរបស់កម្ពុជាក៏គួរតែលើកយកមកពិភាក្សាផងដែរ ។ ដោយយោងទៅលើកិច្ច ព្រមព្រៀងរបស់អង្គការ ពាណិជ្ជកម្មពិភពលោក ស្តីអំពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ វិធានពិសេសសំរាប់គ្រប់គ្រងការធ្វើពាណិជ្ជកម្ម សំលៀកបំពាក់ នឹងត្រូវផុតរលត់នៅថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៥ ខាងមុខនេះ ។ វិធាននេះអនុញ្ញាតអោយប្រទេសជាសមាជិកអនុវត្តការ ដាក់កំហិតលើបរិមាណនាំចូលផលិតផលសំលៀកបំពាក់ នៅក្នុងទីផ្សាររបស់ខ្លួន ។ ដូច្នេះ ហើយការនាំចេញសំលៀកបំពាក់ពីបណ្តាប្រទេសជាសមាជិកស្ទើរតែទាំងអស់ទៅកាន់ទីផ្សារ ធំៗ ជាពិសេសសហរដ្ឋអាមេរិក ត្រូវជាប់កូតា ។ ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៥ តទៅ ប្រទេសជាសមាជិកទាំងអស់ត្រូវលុបបំបាត់ការដាក់កូតានាំចូលសំលៀកបំពាក់ពីបណ្តាប្រទេស ជាសមាជិកនានា ។ ចាប់ពីថ្ងៃនោះតទៅ ការនាំចេញផលិតផលសំលៀកបំពាក់ទៅទីផ្សារ ពិភពលោកនឹងគ្មានការដាក់កំហិតទៀតទេ ចំពោះប្រទេសជាសមាជិកអង្គការពាណិជ្ជកម្ម ពិភពលោកទាំងអស់ ។ ប្រសិនបើកម្ពុជា មិនអាចចូលជាសមាជិកបាននៅថ្ងៃនោះ បណ្តា ប្រទេសនានា នឹងនៅតែបន្តដាក់កូតាលើការនាំចេញសំលៀកបំពាក់ពីកម្ពុជា ។ ដូច្នេះ បើកម្ពុជា មិនអាចចូលជាសមាជិកអង្គការ ពាណិជ្ជកម្មពិភពលោក នៅត្រឹមថ្ងៃទី ០១ ខែមករា ឆ្នាំ២០០៥ ទេនោះនឹងបណ្តាលអោយឧស្សាហកម្មកាត់ដេរសំលៀកបំពាក់កម្ពុជាបាត់លទ្ធភាពប្រកួត ប្រជែងរបស់ខ្លួន ។

## ការបង្កើតយុទ្ធសាស្ត្រ នៃការចរចាចូលជាសមាជិក អង្គការពាណិជ្ជកម្មពិភពលោក

ដោយយកចិត្តទុកដាក់ពិចារណាលើចំណុចទាំងអស់ខាងលើ អនុញ្ញាតអោយក្រុម អ្នកចរចារបស់យើង បង្កើតបាននូវគោលការណ៍ណែនាំទូលំទូលាយសំរាប់ការចរចាជាមួយ

សមាជិកនានា នៃអង្គការពាណិជ្ជកម្មពិភពលោក ។ គោលការណ៍ណែនាំនេះត្រូវបានរៀបចំឡើងសំដៅធានាថា យុទ្ធសាស្ត្រនៃការចរចារបស់យើងនៅអង្គការពាណិជ្ជកម្មពិភពលោកស្របគ្នាទាំងស្រុងទៅនឹងទស្សនៈនៃតួនាទីដ៏សំខាន់របស់ពាណិជ្ជកម្មអន្តរជាតិ ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅកម្ពុជា ។ ចំណុចសំខាន់ទាំង៦ នៃយុទ្ធសាស្ត្ររបស់យើងគឺ :

១- **<u>ពេលវេលា</u>** : យើងដាក់ផែនការចរចារហ័ស ដើម្បីបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។ ភាពចាំបាច់ក្នុងការចូលជាសមាជិកអោយបានរហ័ស គឺត្រូវបានជំរុញដោយការកំណត់ពេលត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ ដែលជាពេលវេលាដែលបណ្តាលអោយឧស្សាហកម្មកាត់ដេរសំលៀកបំពាក់មានផលប៉ះពាល់ដូចបានពន្យល់រួចហើយពីខាងដើម ។ ប៉ុន្តែយើងក៏មានជំនឿផងដែរលើផលប្រយោជន៍របស់កម្ពុជាក្នុងការធានាដល់ការបើកទីផ្សារសំរាប់នាំចេញអោយបានរហ័យ តាមរយៈសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។ ច្រើនជាងនេះទៅទៀត យើងមានជំនឿថា សេចក្តីសំរេចរបស់អគ្គក្រុមប្រឹក្សានៃអង្គការពាណិជ្ជកម្មពិភពលោក អំពីការចរចាចូលជាសមាជិករបស់បណ្តាប្រទេសក្រីក្រ ដូចដែលបានរៀបរាប់ជូនខាងដើមស្រាប់អាចធ្វើអោយគោលដៅនៃការចរចាឆាប់រហ័សរបស់កម្ពុជាប្រព្រឹត្តទៅបាន ។ យើងយល់ថា យើងត្រូវការធ្វើសេចក្តីព្រាង និង អនុម័តនូវច្បាប់មួយចំនួនធំ ដើម្បីបង្កើតអោយមានរបបពាណិជ្ជកម្មមួយស្របជាមួយនឹងវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក ។ ប៉ុន្តែយើងក៏យល់ដែរថា សេចក្តីសំរេចរបស់អគ្គក្រុមប្រឹក្សានឹងអនុញ្ញាតអោយយើងមានពេលវេលាសំរាប់ធ្វើផ្នែកខ្លះ ដែលនៅសេសសល់បន្ទាប់ពីការបានចូលជាសមាជិក ។ម្យ៉ាងទៀតកម្ពុជាមិនបានបង្កើតអោយមានឧស្សាហកម្មក្នុងស្រុក ដែលតំរូវអោយមានការការពារពីការយកពន្ធខ្ពស់លើផលិតផលនាំចូលដើម្បីអោយឧស្សាហកម្មក្នុងស្រុកនោះអាចប្រកួតប្រជែងបាននោះទេ ។ ដូច្នេះការតំរូវអោយមានពេលវេលាគ្រប់គ្រាន់ ដើម្បីអោយឧស្សាហកម្មក្នុងស្រុកសំរបសំរួលបានបន្ទាប់ពីការកាត់បន្ថយពន្ធនាំចូល ដែលជាលទ្ធផលនៃការចរចាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនោះមិនមែនជាការណ៍មួយ ដែលត្រូវយកចិត្តទុកដាក់ពិចារណានោះទេ ។

ជាសង្ខេប យើងមានហេតុផលជាច្រើនក្នុងការបង្កើនល្បឿន នៃការចរចារចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ហើយគ្មានហេតុផលណាមួយក្នុងការពន្យារពេលនៃការចូលជាសមាជិកនោះទេ ។

**២-<u>ការធ្វើសមាហរណកម្មពន្ធគយ:</u>** នៅមុនពេលចរចាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកចាប់ផ្តើមតែបន្តិចប៉ុណ្ណោះ កម្ពុជាបានកែទម្រង់លើរបបពន្ធគយរបស់ខ្លួន ។ ការកែទម្រង់នៅពេលនោះ បានកាត់បន្ថយក្រុមពន្ធគយពី ១២ ក្រុម ទៅ ៤ក្រុម ។ ដូច្នេះបន្ទាប់ពីការកែទម្រង់ ទំនិញនាំចូលទាំងអស់ ជាប់ពន្ធត្រឹមអត្រា ០ភាគរយ ៧ភាគរយ ១៥ភាគរយ រឺ ៣៥ភាគរយ ។ ក្នុងដំណើរនៃការកែទម្រង់ យើងបានលុបចោលនូវអត្រាពន្ធខ្ពស់ជាងនេះ ដែលធ្លាប់បានអនុវត្តកន្លងមក ។ យើងមានជំនឿថា ការកាត់បន្ថយពន្ធនាំចូល និងធ្វើការសាមញ្ញកម្មបែបនេះ ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់យើង ព្រមទាំងរួមវិភាគទានដល់ការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មនៃពិភពលោកនេះ ។ យើងក៏ដឹងផងដែរ អំពីសេចក្តីត្រូវការក្នុងការរក្សាទុកនូវការការពារខ្លះ ចំពោះសហគ្រាសធុនតូច និងធុនមធ្យមរបស់យើង ពិសេសវិស័យកសិកម្ម ។ ម្យ៉ាងទៀត ពន្ធលើការនាំចូលជាចំណែកមួយយ៉ាងសំខាន់នៃចំណូលថវិកាជាតិ ។ ដោយហេតុផលទាំងអស់ខាងលើនេះ ហើយបានជាក្នុងរយៈពេលនៃការចរចា យើងបានសំរេចថា មិនធ្វើការសន្យាក្នុងការកាត់បន្ថយពន្ធនាំចូលបន្ថែមទៀតទេ ។

**៣-<u>ទិសដៅនៃការនាំចេញ:</u>** ដើម្បីអាចប្រកួតប្រជែងបាននៅលើទីផ្សារពិភពលោក ឧស្សាហកម្មនាំចេញ ត្រូវតែមានលទ្ធភាពក្នុងការរកទិញវត្ថុធាតុដើមផ្សេងៗតាមតំលៃទីផ្សារពិភពលោក។ កម្ពុជាជានិច្ចជាកាលបានទទួលស្គាល់នូវចំណុចដ៏សំខាន់នេះ ហើយតាមរយៈច្បាប់វិនិយោគទុនបានអនុញ្ញាតអោយឧស្សាហកម្មនាំចេញមានសិទ្ធិនាំចូលនូវទុនទំនិញពាក់កណ្តាលសំរេច និងវត្ថុធាតុដើមសំរាប់បំរើផលិតកម្មដោយមិនបង់ពន្ធ លើការនាំចូល ។ ប៉ុន្តែអ្វីដែលកម្ពុជាបានធ្វើនៅពេលនេះ គឺមិនស្របទៅនឹងវិធានរបស់អង្គការពាណិជ្ជកម្ម

ពិភពលោកទេ ។ ទោះបីយ៉ាងណាក៏ដោយ យើងយល់ថាការរក្សាទុកនូវសិទ្ធិពិសេសនេះ គឺមានសារៈសំខាន់ចំពោះឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងលទ្ធភាពចំពោះនៃការទាក់ទាញវិនិយោគសំរាប់ការនាំចេញនាពេលអនាគតរបស់យើង ។ ដូច្នេះ យើងសំរេចរក្សាទុកសិទ្ធិក្នុងការផ្តល់សិទ្ធិពិសេសនេះ ទោះបីផ្ទុយជាមួយវិធានអង្គការពាណិជ្ជកម្មពិភពលោកក៏ដោយ ។

**៤-ធ្វើអោយបរិយាកាសវិនិយោគល្អប្រសើរ និងគាំទ្រការវិនិយោគផ្ទាល់ពីបរទេសៈ**

ដូចបានជំរាបជូនខាងដើមរួចមកហើយ កំណើននៃការនាំចេញ និងកំណើននៃបង្កើតការងារថ្មី គឺអាស្រ័យទាំងស្រុងលើកំណើននៃការធ្វើវិនិយោគ ជាពិសេសការវិនិយោគផ្ទាល់ពីបរទេស ។ យើងបានដឹងពីចំណុចនេះ ដូច្នេះហើយ ចំណុចសំខាន់នៃការប្រើប្រាស់សមាជិកភាព របស់យើងក្នុងអង្គការពាណិជ្ជកម្មពិភពលោកគឺជាមធ្យោបាយមួយបង្កើនភាពទាក់ទាញ របស់កម្ពុជាឱ្យទៅជាកន្លែងសំរាប់ធ្វើវិនិយោគមួយ ។ សមាជិកភាពនៃអង្គការពាណិជ្ជកម្មពិភពលោកផ្តល់នូវមធ្យោបាយបី ក្នុងការធ្វើបែបនេះ :

**ទីមួយ:** សមាជិកភាពនៃអង្គការពាណិជ្ជកម្មពិភពលោកផ្តល់ការធានាជាក់លាក់មួយចំពោះអ្នកវិនិយោគ ដែលមានបំណងធ្វើផលិតកម្មនៅកម្ពុជា ដើម្បីនាំចេញទៅកាន់ទីផ្សារនានានៃពិភពលោក ។ នោះគឺដោយសារអ្នកនាំចេញជឿជាក់ថា ទំនិញនាំចេញរបស់ខ្លួនត្រូវជាប់ពន្ធក្នុងប្រទេសនាំចូលក្នុងអត្រាមិនខ្ពស់ជាងទំនិញដូចគ្នា រឺស្រដៀងគ្នា ដែលនាំចូលពីប្រទេសផ្សេងៗទៀត ។ គោលការណ៍នេះ ហៅថាគោលការណ៍ស្មើភាពនៃប្រជាជាតិទទួលបានការអនុគ្រោះបំផុត។ ក្រៅពីនេះ ដោយសារប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកភាគច្រើន បានចងអត្រាពន្ធលើទំនិញនាំចូល អ្នកនាំទំនិញចេញពីកម្ពុជា អាចដឹងពីអត្រាពន្ធខ្ពស់បំផុតដែលត្រូវបង់លើទំនិញរបស់ខ្លួន នៅក្នុងបណ្តាប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។ម្យ៉ាងទៀតអ្នកនាំចេញ ទំនិញពីកម្ពុជាអាចដឹងផងដែរថា ទំនិញរបស់ខ្លួនមិនជាប់កូតា រឺការដាក់កំហិតលើបរិមាណនាំចេញនៅលើទីផ្សារនាំចេញនោះទេ (ចំពោះផលិតផលសំលៀកបំពាក់ ត្រូវអនុវត្តចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៥) ។ ដោយសារហេតុផលទាំងអស់នេះហើយ សមាជិកភាពនៃអង្គការពាណិជ្ជកម្មពិភពលោកជួយកាត់បន្ថយភាព

មិនប្រាកដចំពោះវិនិយោគិន ដែលមានបំណងមកវិនិយោគនៅកម្ពុជាសំរាប់នាំចេញទៅទីផ្សារនៃបណ្តាប្រទេសនានា (ចំពោះវិនិយោគិន ដែលចង់នាំចេញទៅបណ្តាប្រទេសជាសមាជិកអាស៊ានត្រូវអនុវត្តតាមលក្ខខ័ណ្ឌរបស់អាស៊ាន) ។

**ទីពីរ:** សមាជិកភាពរបស់អង្គការពាណិជ្ជកម្មពិភពលោក តំរូវអោយកម្ពុជាបំពេញការងារជាច្រើន ក្នុងការបង្កើតអោយមាននូវក្របខ័ណ្ឌច្បាប់សំរាប់គ្រប់គ្រងពាណិជ្ជកម្មអោយបានគ្រប់គ្រាន់ ។ រាជរដ្ឋាភិបាលកម្ពុជា បានចូលរួមយ៉ាងសកម្មក្នុងការបង្កើត និងដាក់ជូនសភាជាតិនូវច្បាប់សំខាន់ៗ ដែលមានលក្ខណៈទំនើបសេរី និងត្រឹមត្រូវសំរាប់គ្រប់គ្រងការធ្វើពាណិជ្ជកម្ម ។ ជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក ប្រទេសមួយត្រូវតែមានច្បាប់គ្រប់គ្រងការធ្វើពាណិជ្ជកម្មអន្តរជាតិស្របជាមួយនឹងវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក ។ កម្ពុជាយល់ស្របជាមួយនឹងលក្ខណៈបែបនេះ និងយល់ថាជាការចាំបាច់ ហើយបានស្វាគមន៍នូវតំរូវការទាំងឡាយ នឹងជំរុញអោយកម្ពុជាបង្កើនល្បឿនក្នុងការបង្កើតអោយមាននូវក្របខ័ណ្ឌច្បាប់មួយសំរាប់គ្រប់គ្រងការធ្វើពាណិជ្ជកម្ម ដែលស្របតាមស្តង់ដារអន្តរជាតិ ។

**ទីបី:** កម្ពុជាយល់ឃើញថា លក្ខណៈនៃការការទាក់ទាញវិនិយោគិនរបស់កម្ពុជាគឺអាស្រ័យលើភាពមានគ្រប់គ្រាន់នូវហេដ្ឋារចនាសម្ព័ន្ធសំរាប់ការធ្វើពាណិជ្ជកម្ម ។ ហេដ្ឋារចនាសម្ព័ន្ធនេះ រួមមានសេវាកម្មនានា ដូចជាទូរគមនាគមន៍ ការដឹកជញ្ជូន ធនាគារ គណនេយ្យកម្ម និង សវនកម្ម ។ បរិយាកាសនៃការវិនិយោគ ក៏អាចធ្វើអោយប្រសើរបានដែរ តាមរយៈការអប់រំ និងហ្វឹកហ្វឺនកំលាំងពលកម្ម ។ កម្ពុជាដឹងថា ការចរចាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក លើការបើកទីផ្សារវិស័យសេវាកម្ម គឺជាឱកាសមួយ ដើម្បីលើកទឹកចិត្ត វិនិយោគិនផ្ទាល់ពីបរទេសអោយវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសេវាកម្មគន្លឹះ មួយចំនួនហើយក៏ជាឱកាសមួយដែលក្នុងការធ្វើអោយប្រសើរឡើងនូវបរិយាកាសចំពោះការធ្វើ ពាណិជ្ជកម្មជំនាញ ។ ដូចគ្នានេះដែរ ការវិនិយោគលើការអប់រំពីបរទេស និងហ្វឹកហ្វឺនមនុស្សពេញវ័យ នឹងជួយបង្កើនពលកម្ម ដែលចាំបាច់សំរាប់ទាក់ទាញឧស្សាហកម្មជំនាញ និងដើម្បីបង្កើនចំណូល ។

ដោយសារមូលហេតុទាំងនេះហើយ កម្ពុជាយល់ថា ការចរចាររបស់យើងលើវិស័យសេវាកម្មអាចធ្វើអោយប្រសើរថែមទៀតនូវយុទ្ធសាស្ត្រទូទៅរបស់យើងក្នុងការកែលំអបរិយាកាសពាណិជ្ជកម្មនៅកម្ពុជា។ យើងបានដឹងថា សេចក្តីសំរេចរបស់អគ្គក្រុមប្រឹក្សាអង្គការពាណិជ្ជកម្មពិភពលោក (សូមអានខាងលើ) អំពាវនាវអោយប្រទេសជាសមាជិកកំរិតនូវទំហំនៃការចរចាលើវិស័យសេវាកម្ម ។ ទោះជាយ៉ាងណាក៏ដោយ ជាជាងប្រឹងប្រែងកំរិតលើការសន្យារបស់យើងអោយនៅត្រឹមកំរិតទាបបំផុតនោះ កម្ពុជាជ្រើសយកការចរចាបើកទីផ្សារសេវាកម្មដោយពិនិត្យលើ វិស័យសេវាកម្មជាក់ស្តែងនីមួយៗ ហើយដែលការធ្វើសេរីភាវូបនីយកម្មលើវិស័យសេវាកម្មទាំងនោះ នឹងជួយជំរុញអោយកម្ពុជាឆ្ពោះទៅកាន់គោលដៅអភិវឌ្ឍន៍ទូលំទូលាយជាង ហើយកម្ពុជាបានរៀបចំចរចា និងទទួលយកការសន្យាលើវិស័យសេវាកម្ម តាមបែបនោះ ។

៥-<u>**ការរក្សាទុកជំរើសគោលនយោបាយ និងភាពអាចប្រែប្រួលបានចំពោះវិស័យកសិកម្ម:**</u> ការបើកចំហរទីផ្សារ (ចំណុចទី១ខាងលើ) និងការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគទុន (ចំណុចទី៤ខាងលើ) នឹងផ្តល់ផលប្រយោជន៍ដល់វិស័យកសិកម្ម ក៏ដូចជាវិស័យសេវាកម្ម និងផលិតកម្ម ។ ទោះជាយ៉ាងណាក៏ដោយ យើងដឹងថា មានវិធានពិសេសខ្លះនៃវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក ដែលអនុញ្ញាតិអោយរដ្ឋាភិបាលអាចផ្តល់ការឧបត្ថម្ភធនដល់វិស័យកសិកម្មបាន ។ វិធានទាំងនេះត្រូវបានធ្វើឡើង ដើម្បីធានាថា វិធានការគាំទ្រដែលធ្វើអោយប៉ះពាល់ដល់ការធ្វើពាណិជ្ជកម្ម មិនត្រូវបានអនុញ្ញាត្តិអោយយកមកប្រើប្រាស់ឬបង្កើនសកម្មភាពទេ ហើយវិធានការកំពុងអនុវត្តបច្ចុប្បន្ន ដែលប៉ះពាល់ដល់ការធ្វើពាណិជ្ជកម្មត្រូវកាត់បន្ថយជាបណ្តើរៗអោយនៅចំនួនតិចបំផុត ។ យើងជឿជាក់ថា កម្ពុជាគឺជាប្រទេសដែលអាចប្រកួតប្រជែងបានរឺមានសក្តានុពលក្នុងការប្រកួតប្រជែងលើផលិតផលកសិកម្មជាច្រើនមុខ ។ វិធានដែលតំរូវអោយកាត់បន្ថយការឧបត្ថម្ភធន ផ្តល់ដោយបណ្តាប្រទេសដទៃដល់អ្នកផលិតអាចផ្តល់ជាផលប្រយោជន៍ ។ ទោះបីយ៉ាងណាក៏ដោយ ដូចបានរៀបរាប់ជូន

ដល់អ្នកផលិតអាចផ្តល់ជាផលប្រយោជន៏ ។ ទោះបីយ៉ាងណាក៏ដោយ ដូចបានរៀបរាប់ជូនខាងលើយើងយល់ថា កម្ពុជាត្រូវរក្សាទុកការការពារតាមរយៈពន្ធគយអោយនៅកំរិតទាបបំផុត ប៉ុន្តែគ្រប់គ្រាន់សំរាប់ការការពារផលិតផលកសិកម្ម និង រក្សាសិទ្ធិក្នុងការផ្តល់ការឧបត្ថម្ភធនចំពោះអ្នកផលិតក្នុងស្រុក ដើម្បីជួយអោយពួកគេអោយអាចប្រកួតប្រជែងបានជាងមុន ។ ការសំរេចបានដូចនេះ គឺជាកត្តាដ៏សំខាន់នៃយុទ្ធសាស្ត្ររបស់យើងក្នុងការចរចាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។

**៦-ការធានាអោយបាននូវផលប្រយោជន៏ជាប្រទេសក្រីក្រចំពោះសុខភាពសាធារណៈ**

នាសន្និសីទថ្នាក់រដ្ឋមន្ត្រី នៅទីក្រុងដូហា នៅឆ្នាំ២០០១ អង្គការពាណិជ្ជកម្មពិភពលោកបានអនុម័តលើសេចក្តីប្រកាសមួយ ដែលផ្តល់អោយប្រទេសក្រីក្រនូវសិទ្ធិពិសេសមួយចំនួនទាក់ទិននឹងលក្ខខ័ណ្ឌតម្រូវរបស់អង្គការពាណិជ្ជកម្មពិភពលោក សំរាប់ការពារប្រកាសនីយប័ត្រតក្កកម្មលើផលិតផលឱសថ ។ គោលបំណងនៃសេចក្តីប្រកាសនេះ និងសេចក្តីសំរេចផ្សេងៗសំរាប់ការអនុវត្តន៏ជាបន្តបន្ទាប់ គឺដើម្បីអនុញ្ញាតអោយបណ្តាប្រទេសក្រីក្រអាចទទួលបាននូវសិទ្ធិក្នុងការផលិតថ្នាំពេទ្យដែលអាចមានតំលៃថោក រួមទាំងសិទ្ធិក្នុងការនាំចូល ផលិតផលឱសថដែលមានតំលៃថោកផងដែរ ។ ប្រការចែងនេះមានសារៈសំខាន់ណាស់សំរាប់កម្ពុជា ដោយយើងមានបញ្ហាលំបាក ផ្នែកសុខាភិបាលសាធារណៈ ដូចជា ជម្ងឺហ៊ីវ អេដស៏ របេង អាសន្នរោគ និងជម្ងឺឆ្លងផ្សេងទៀត ។ ជាមួយគ្នានេះ ដែរ យើងពឹងពាក់ទាំងស្រុងលើការនាំចូលថ្នាំពេទ្យដើម្បីប្រឆាំងនឹងជម្ងឺទាំងនោះ ប៉ុន្តែធនធានហិរញ្ញវត្ថុរបស់យើងមានកំរិត ។ ហេតុដូច្នេះវាមានសារៈសំខាន់ខ្លាំងណាស់ ដែលយើងគួរទទួលបានថ្នាំពេទ្យក្នុងតំលៃទាបបំផុតតាមតែអាចធ្វើបាន ។ ការធានាបានថា សេចក្តីប្រកាសរបស់អង្គការពាណិជ្ជកម្មពិភពលោក អាចអនុវត្តបានយ៉ាងពេញលេញចំពោះកម្ពុជានោះ គឺជាគោលបំណងយ៉ាងសំខាន់ នៃការចរចារបស់យើង ។

កត្តាទាំងអស់នេះហើយ គឺជាការពិចារណាចំបង ដែលយើងពិចារណាក្នុងការចរចាជាមួយសមាជិកនានា នៃអង្គការពាណិជ្ជកម្មពិភពលោក ។

# ការចរចាចូលជាសមាជិក

## ការកំណត់ដំណើរការចរចា

កម្ពុជាបានដាក់ពាក្យស្នើសុំចូលជាសមាជិក នៅក្នុងអង្គការពាណិជ្ជកម្មពិភពលោកជាដំបូង នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៤ ។ ក្រុមការងារពិនិត្យការចូលជាសមាជិករបស់កម្ពុជាត្រូវបាន បង្កើតនៅថ្ងៃទី ២១ ខែធ្នូ ឆ្នាំ១៩៩៤។ ក៏ប៉ុន្តែរហូតមកដល់ឆ្នាំ ១៩៩៧ ទើបយើងអាចនៅ ធ្វើកិច្ចការចាំបាច់មួយចំនួន ដើម្បីកំណត់ដំណើរការចរចា នៃការសុំចូលជាសមាជិកបាន។

ជំហានទី១ក្នុងដំណើរការសុំចូលជាសមាជិក គឺប្រទេសជាបេក្ខភាពស្នើសុំត្រូវរៀបចំ "អនុស្សារណៈស្តីពីរបបពាណិជ្ជកម្មក្រៅប្រទេស "។ អនុស្សារណៈនេះត្រូវរៀបរៀងឡើង ដើម្បីជូនដំណឹងទៅសមាជិក នៃអង្គការពាណិជ្ជកម្មពិភពលោកអំពីច្បាប់បទបញ្ជា និងសេចក្តីសំរេច ព្រមទាំងគោលនយោបាយរបស់រដ្ឋាភិបាលទាំងអស់ ដែលជះឥទ្ធិពលលើការធ្វើពាណិជ្ជកម្ម ។ អនុស្សារណៈត្រូវធ្វើឡើងតាមឯកសារណែនាំរបស់អង្គការពាណិជ្ជកម្មពិភពលោក ដែលកម្ពុជាត្រូវអធិប្បាយគ្របដណ្តប់លើគ្រប់ចំណុចទាំងអស់នៃឯកសារណែនាំនេះ។ ប្រធានបទសំខាន់ៗ ដែលត្រូវគ្របដណ្តប់ដោយអនុស្សារណៈនោះរួមមាន:

- គោលនយោបាយរូបិយវត្ថុ និងសារពើពន្ធ
- គោលនយោបាយស្តីពីកម្មសិទ្ធិរដ្ឋ និងឯកជនភាវូបនីយកម្ម
- គោលនយោបាយថ្លៃ និងការប្រកួតប្រជែង
- បណ្តាវិធានទាក់ទិននឹងសិទ្ធិនៃការធ្វើពាណិជ្ជកម្ម
- នីតិវិធីគយ ជាពិសេសនីតិវិធីនៃការវាយតំលៃពន្ធគយ
- ការអនុវត្តនីការប្រមូលពន្ធក្នុងស្រុកចំពោះទំនិញនាំចូល
- ការដាក់កំហិតលើបរិមាណនាំចូល ការកំណត់កូតា និងអាជ្ញាប័ណ្ណនាំចូល
- ការត្រួតពិនិត្យទំនិញមុនពេលផ្ទុក
- ការប្រឆាំងនឹងការលក់បង្ខូចថ្លៃ ពន្ធតបត និងការការពារ

- បទបញ្ញាស្តីពីការនាំចេញ
- ស្តង់ដារផលិតផល និងបទបញ្ញាបច្ចេកទេស
- បទបញ្ញាអនាម័យ និងភូតគាមអនាម័យ
- វិធានការស្តីពីការវិនិយោគទុន ពាក់ព័ន្ធនឹងពាណិជ្ជកម្ម
- ការធ្វើពាណិជ្ជកម្មរបស់ក្រុមហ៊ុនរដ្ឋ
- តំបន់សេរី និងតំបន់សេដ្ឋកិច្ចពិសេស
- លទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល
- គោលនយោបាយកសិកម្ម
- ការការពារកម្មសិទ្ធិបញ្ញា
- គោលនយោបាយដែលប៉ះពាល់ដល់ការធ្វើពាណិជ្ជកម្មលើសេវាកម្ម

រាជរដ្ឋាភិបាលបានចាត់ទុកថា កិច្ចការដ៏ស្មុគស្មាញនៃការរៀបចំអនុស្សរណៈ និងការចាត់ចែងចំពោះការចរចា តម្រូវអោយមានយន្តការថ្មីនិងពិសេសរបស់រដ្ឋាភិបាល ។ រដ្ឋាភិបាលបានណែនាំក្រសួងពាណិជ្ជកម្មអោយធ្វើជាអ្នកសំរបសំរួលសកម្មភាព ចំពោះការសុំចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ។ បន្ថែមលើនេះ រដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការសំរបសំរួលអន្តរក្រសួងស្តីពីការសុំចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោកក្រោមអធិបតីភាពរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម កាលពីខែកញ្ញា ឆ្នាំ ១៩៩៧ ។ គណៈកម្មាធិការនេះមានសមាជិកថ្នាក់នយោបាយចំនួន ១៥រូប ហើយមន្ត្រីជំនាញ ៣រូបមកពីក្រសួងនីមួយៗក្នុងចំណោមក្រសួងចំនួន២៣ ។ តួនាទីរបស់គណៈកម្មាធិការនេះរួមមានៈ (i) សំរបសំរួលបញ្ហានយោបាយដែលទាក់ទងនឹងការចរចាសុំចូលជាសមាជិក នៃអង្គការពាណិជ្ជកម្ម ពិភពលោក (ii) បរិយាយអំពីគោលការណែនាំ ដើម្បីអនុវត្តកិច្ចព្រមព្រៀងនៃអង្គការពាណិជ្ជកម្មពិភពលោក (iii) រៀបចំឯកសារចាំបាច់នានា (iv) កំណត់នូវអាទិភាព របស់រដ្ឋាភិបាលក្នុងគោលនយោបាយពាណិជ្ជកម្មក្រៅប្រទេស (v) ធានានូវការសំរបសំរួលក្នុងចំណោមបណ្តាក្រសួង ស្ថាប័ន (vi) រាយការណ៍ជូនសម្តេចនាយករដ្ឋមន្ត្រីនូវបញ្ហាទាក់ទងទៅនឹងការសុំចូលអង្គការពាណិជ្ជកម្មពិភពលោក ។

ជាមួយនឹងយន្តការនេះ ក្រុមការងារអង្គការពាណិជ្ជកម្មពិភពលោករបស់រដ្ឋាភិបាល បានដំណើរការ ដោយចាប់ផ្តើមការងាររៀបចំអនុស្សារណៈ ស្តីពីរបបពាណិជ្ជកម្ម ។ សេចក្តីព្រាង លើកទី១ បានបញ្ចប់នៅក្នុង ឆ្នាំ១៩៩៩ ហើយបន្ទាប់ពីការត្រួតពិនិត្យជាច្រើនលើកមក សេចក្តីព្រាងចុងក្រោយ ត្រូវបានដាក់ជូនទៅអង្គការពាណិជ្ជកម្មពិភពលោកនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩។ អនុស្សារណៈ រួមមានជាង១០០ទំព័រ និង៦ផ្នែក សំខាន់ៗពិពណ៌នា អំពីរបបពាណិជ្ជកម្មកម្ពុជា ជាមួយនឹងតារាងស្ថិតិមួយចំនួន ។ អនុស្សារណៈត្រូវបានដាក់ជូន ទៅសមាជិកនៃក្រុមការងារពិនិត្យការសុំចូលជាសមាជិក ដើម្បីនឹងអនុវត្តតាមលំដាប់ធម្មតា របស់អង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជា ហើយបន្ទាប់មកដាក់ជូនកម្ពុជានូវសំណួរ ចំនួន៧៥សំណួរ ដើម្បីបំភ្លឺបន្ថែមលើទិដ្ឋភាព នៃរបបពាណិជ្ជកម្មកម្ពុជា ។ យើងបាន ផ្តល់ចំលើយលើសំណួរទាំងនោះ ហើយបន្ទាប់មករៀបចំកិច្ចប្រជុំលើកទី១ នៃក្រុមការងារ ត្រួតពិនិត្យការសុំចូលជាសមាជិករបស់កម្ពុជា និងចាប់ផ្តើមនូវការចរចា ។

## ដំណើរការនៅទីក្រុងហ្សឺណែវ

កិច្ចប្រជុំក្រុមការងារលើកទី១ ស្តីពីការសុំចូលរបស់កម្ពុជាក្នុងអង្គការពាណិជ្ជកម្ម ពិភពលោក ត្រូវបានប្រារព្ធ ធ្វើនៅខែឧសភា ឆ្នាំ២០០១ ហើយកិច្ចប្រជុំជាបន្តបន្ទាប់ បានប្រារព្ធធ្វើនៅទីចាត់ការរបស់អង្គការពាណិជ្ជកម្មពិភពលោក នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ។ ពេលខ្លះនៅមុនពេលដែលកិច្ចប្រជុំទាំងអស់នេះចាប់ផ្តើម យើងមានឱកាសបាន ទទួលជំនួយបច្ចេកទេសដែលផ្តល់អោយដោយអង្គការសហប្រជាជាតិ ស្តីពីពាណិជ្ជកម្ម និងការ អភិវឌ្ឍន៍ (UNCTAD)។ ជំនាញការរបស់អង្គការនេះមានបទពិសោធន៍យ៉ាងច្រើនអំពី ដំណើរការសុំចូលក្នុងអង្គការពាណិជ្ជកម្មពិភពលោក ហើយអាចផ្តល់នូវសេចក្តីពន្យល់ដល់ ក្រុមអ្នកចរចារបស់យើងអំពីរបៀបចរចា ដែលធ្លាប់បានប្រព្រឹត្តទៅ ដែលជាហេតុធ្វើយើង យល់បានពីអ្វី ដែលអាចកើតមានឡើងក្នុងការចរចា។ ជំនាញការទាំងនោះ បានជួយធ្វើអោយ

ដំណើរការនៃការសុំចូលជាសមាជិករបស់យើងប្រព្រឹត្តទៅក្នុងគោលដៅ នៃការអភិវឌ្ឍន៍ទៅមុខ ។ ពួកគេបានបន្តជួយរហូតដល់ចុងបញ្ចប់នៃការចរចា ហើយជំនួយនេះគឺជា អត្ថប្រយោជន៍យ៉ាងធំសម្បើមសំរាប់កម្ពុជា។

កិច្ចប្រជុំលើកទី១ រួមមានការពិនិត្យលើអនុស្សារណៈ ស្តីពីរបបពាណិជ្ជកម្មកម្ពុជា និងចំលើយដែលកម្ពុជាបានឆ្លើយចំពោះសំនួររបស់បណ្តាប្រទេសជាសមាជិក ។ ករណីនេះជានិច្ចជាកាលតែងតែត្រូវធ្វើឡើងចំពោះរាល់ការស្នើសុំចូលរបស់បណ្តាប្រទេសទាំងអស់ ហើយការពិនិត្យបែបនេះនឹងបង្កើតនូវសំណើរសំរាប់ពត៌មានបន្ថែមទៀត។ នៅចុងបញ្ចប់នៃកិច្ចប្រជុំយើងត្រូវបានសមាជិកនានា ស្នើអោយផ្តល់នូវការឆ្លើយតបទៅនឹងសំនួរមានលក្ខណៈលំអិតដែលលេខាធិការដ្ឋាននៃអង្គការពាណិជ្ជកម្មពិភពលោក បានបង្កើតឡើងសំរាប់វិស័យសេវាកម្មអាជ្ញាប័ណ្ណនាំចូល ការការពារកម្មសិទ្ធិបញ្ញា ការឧបត្ថម្ភលើវិស័យកសិកម្ម របាំងបច្ចេកទេសពាណិជ្ជកម្ម និង បទបញ្ជាអនាម័យ និងភូតគាមអនាម័យ ។ យើងក៏ត្រូវបានសមាជិកស្នើសុំអោយផ្តល់សម្បទាន លើផ្នែកទំនិញ និងសេវាកម្ម ដែលកម្ពុជាអាចផ្តល់បាន ។

ក្នុងរយៈពេលប៉ុន្មានខែ បន្ទាប់ពីកិច្ចប្រជុំលើកទី១ ក្រុមការងារទទួលបន្ទុកកិច្ចការអង្គការពាណិជ្ជកម្មពិភពលោក បានបំពេញកិច្ចការទាំងអស់នេះ។

ក្នុងការរៀបចំសម្បទានពន្ធគយ យើងបានពិចារណាលើអង្គហេតុដែលសមាជិកនានាតម្រូវឱ្យប្រទេសកំពុងសុំចូលចងគ្រប់អត្រាពន្ធគយទាំងអស់ ។ នេះមានន័យថា យើងត្រូវកំណត់អត្រាចងលើរាល់អាត្រានីមួយៗ នៃមុខទំនិញចំនួន ៦៨២៣មុខ ដោយយោងតាមប្រព័ន្ធស្របគ្នា (HS) ឆ្នាំ១៩៩៦ ។ ការចងពន្ធនេះ នឹងកំណត់នូវអាត្រាអតិបរមា ដែលអនុវត្តចំពោះមុខទំនិញទាំងនោះ ។ ជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក កម្ពុជានឹងនៅតែមានសេរីភាពក្នុងការកំណត់អត្រាពន្ធក្នុងកំរិតស្មើ ឬទាបជាងអាត្រាពន្ធចង ក៏ប៉ុន្តែនឹងមិនអាចយកពន្ធលើសអត្រាចងនោះឡើយ លើកលែងតែក្នុងស្ថានភាពលើកលែងមួយចំនួនចេញ ។

យុទ្ធសាស្ត្ររបស់យើង ក្នុងការធ្វើសំណើសម្បទានពន្ធគយជាលើកដំបូងនេះ គឺកំណត់អាត្រាចងរបស់យើង អោយខ្ពស់ជាងអត្រាកំពុងអនុវត្ត មានន័យថាខ្ពស់ជាងអត្រា ដែលយើងកំពុងប្រើ ។ ដូចបានជំរាបជូនខាងលើគោលបំណងរបស់យើងក្នុងការចរចា គឺចៀសវាងការសន្យាណាមួយដែលកាត់បន្ថយអត្រាពន្ធកំពុងអនុវត្ត ហើយយើងត្រូវការរក្សានូវចន្លោះមួយ ដើម្បីការឆ្លើយតបនឹងសំណើបន្ទាបអត្រាចងពន្ធរបស់យើង ក្នុងបំណងរក្សាគោលដៅរបស់យើង ។

ការធ្វើសម្បទានដំបូងអំពីការបើកទីផ្សារវិស័យសេវាកម្ម គឺមានលក្ខណៈស្មុគស្មាញច្រើន ។ ដំបូងគឺត្រូវសំរេចថា វិស័យសេវាកម្មណា ត្រូវដាក់បញ្ចូលក្នុងសំណើសម្បទានដំបូងនោះ ។ គឺមិនដូចករណីទំនិញឡើយ សមាជិកមិនតម្រូវអោយមានការសន្យាលើគ្រប់វិស័យសេវាកម្មទាំងអស់ទេ ។ តាមពិត ដូចបានជំរាបជូនខាងលើ រួចហើយក្នុងករណីប្រទេសក្រីក្រសមាជិកបានព្រមព្រៀងថា ពួកគេតម្រូវអោយមានការសន្យាបើកទូលាយលើវិស័យសេវាកម្មតិចជាងធម្មតា ។ តាមចំណាត់ប្រភេទរបស់ អង្គការពាណិជ្ជកម្មពិភពលោកសំរាប់វិស័យសេវាកម្មរួមមានចំនួន ១២ វិស័យធំៗ និងវិស័យរងចំនួន១៥៥ ហើយយើងត្រូវការជ្រើសរើសក្នុងចំណោមវិស័យ / វិស័យរងទាំងនោះ ដើម្បីដាក់ក្នុងសំណើសម្បទានដំបូងរបស់យើង ។ បន្ថែមលើនេះអង្គការពាណិជ្ជកម្មពិភពលោក បានកំណត់នូវរបៀប ៤យ៉ាង ដែលវិស័យណាក៏ដោយអាចធ្វើការនាំចូលតាមរបៀប៤យ៉ាងនេះ ។ របៀបទាំង៤យ៉ាងនោះរួមមានការផ្គត់ផ្គង់សេវាកម្មឆ្លងកាត់ព្រំដែន (ឧទាហរណ៍ ការបញ្ជាទិញគំនូសស្ថាបត្យកម្មពីស្ថាបត្យករថៃ ហើយគំនូសនោះត្រូវបានបញ្ជូនតាមអ៊ីម៉េលមកភ្នំពេញ ដូចនេះគឺជាការនាំចូលសេវាស្ថាបត្យកម្ម) ការប្រើប្រាស់សេវានៅបរទេស (ឧទាហរណ៍ ការជួសជុលនាវាចំលងនៅឯរោងជាងនាវាវៀតណាម ដូច្នេះពេលដែលនាវាចំលងត្រឡប់មកកម្ពុជាវិញ គឺបាននាំចូលនូវសេវាជួសជុល) វត្តមានក្រុមហ៊ុន (ឧទាហរណ៍ ការអនុញ្ញាតអោយក្រុមហ៊ុនស្ថាបត្យកម្មបរទេសបង្កើតក្រុមហ៊ុននៅកម្ពុជាជួលស្ថាបត្យករកម្ពុជា ដូច្នេះគឺជាការនាំចូលសេវាកម្ម ស្ថាបត្យកម្មរបស់ក្រុមហ៊ុន) និងចលនារបស់កំលាំងពលកម្ម (ឧទាហរណ៍ ការអនុញ្ញាតអោយក្រុមហ៊ុនស្ថាបត្យកម្មបានបង្កើតនៅកម្ពុជា ជួលស្ថាបត្យករបរទេស ដូច្នេះជាការនាំចូលនូវ សេវាកម្ម

នៃបុគ្គលទាំងនោះ) ។ ជាទីបញ្ចប់ ចំពោះវិស័យសេវាកម្ម/សេវាកម្មរង ដែលយើងបានជ្រើសរើសដើម្បីដាក់បញ្ចូលក្នុងសំណើសម្បទាននោះ យើងត្រូវបានគេតម្រូវអោយបង្ហាញចំពោះរបៀបនីមួយៗ នៃរបៀបទាំង៤ ដែលសេវាកម្មត្រូវបានគេនាំចូល គឺកំរិតនៃការបើកច្រកទីផ្សារដែលត្រូវអនុញ្ញាត ហើយត្រូវបញ្ជាក់ថា ការកំណត់សិទ្ធិចំពោះអ្នកផ្គត់ផ្គង់សេវាកម្មបរទេស គឺដូចគ្នាទៅនឹងការ កំរិតសិទ្ធិលើអ្នកផ្គត់ផ្គង់ជនជាតិកម្ពុជាក្នុងវិស័យសេវាកម្មនោះ ។ លក្ខណៈនេះគឺសំដៅលើប្រព្រឹត្តិកម្មជាតិ។ ចំនុចនេះត្រូវបានបញ្ជាក់កាន់តែច្បាស់ឡើងនៅក្នុងការចរចាជាបន្តបន្ទាប់ ដែលសមាជិកតែងតែស្វែងរកនូវការសន្យាដោយមានការបើកច្រកទីផ្សារពេញលេញ និងប្រព្រឹត្តិកម្មជាតិពេញលេញ។

នៅពេលដែលឯកសារទាំងអស់នេះត្រូវបានរៀបចំ និងព្រមព្រៀងដោយរដ្ឋាភិបាលរួចហើយឯកសារទាំងនោះត្រូវបានផ្ញើជូនទៅអង្គការពាណិជ្ជកម្មពិភពលោក ហើយការរៀបចំកិច្ចប្រជុំក្រុមការងារលើកទី២ត្រូវបានកំណត់ ។ កិច្ចប្រជុំលើទី២នេះបានប្រារព្ធធ្វើឡើងនៅដើមឆ្នាំ២០០២ ហើយបង្កើតបានជាទំរង់គំរូមួយសំរាប់ប្រើប្រាស់ក្នុងកិច្ចប្រជុំជាបន្តបន្ទាប់ ដែលត្រូវបានប្រារព្ធធ្វើឡើងក្នុងឆ្នាំ២០០២ និង២០០៣។ ជាការពិត មានសកម្មភាពបីដាច់ដោយឡែកពីគ្នា បានកើតឡើងជារៀងរាល់ពេល នៅពេលដែលយើងធ្វើដំណើរទៅទីក្រុង ហ្សឺណែវ។

ទី១ គឺកិច្ចប្រជុំក្រុមការងារផ្លូវការ ។ សមាជិកអង្គការពាណិជ្ជកម្មពិភពលោកទាំងអស់ដែលមានបំណងបានចូលរួមកិច្ចប្រជុំនេះត្រូវបានអនុញ្ញាតិ ។ កិច្ចបំណងនៃកិច្ចប្រជុំនេះ គឺដើម្បីបន្តពិនិត្យលើច្បាប់ និងបទប្បញ្ញត្តិនានាសំរាប់គ្រប់គ្រងការធ្វើពាណិជ្ជកម្មកម្ពុជា និង អនុញ្ញាតអោយសមាជិកទាំងអស់ពិនិត្យលើសង្គតភាព នៃច្បាប់នេះទៅនឹងវិធាននៃអង្គការពាណិជ្ជកម្មពិភពលោកក្នុងកំរិតណាមួយ ។ ការពិភាក្សានៅក្នុងកិច្ចប្រជុំ បានជួយយើងអោយយល់កាន់តែពេញលេញឡើងពីជំហានដែលយើងត្រូវប្រកាន់យក ដើម្បីធ្វើអោយច្បាប់ និង បទប្បញ្ញត្តិយើងមានសង្គតភាពទៅនឹងវិធាននៃអង្គការពាណិជ្ជកម្មពិភពលោក ។ក្នុងរយៈពេលនេះរដ្ឋាភិបាល បានខិតខំប្រឹងប្រែងក្នុងការធ្វើសេចក្តីព្រាងនិងបញ្ជូនច្បាប់ដែលសមាជិកនៃអង្គការ

ពាណិជ្ជកម្មពិភពលោកតំរូវអោយធ្វើទៅសភាជាតិ ដើម្បីធ្វើការអនុម័ត ។ ឧទាហរណ៍ ការធ្វើសេចក្តីព្រាងច្បាប់គយថ្មី និងសេចក្តីព្រាងក្រមរដ្ឋប្បវេណីថ្មីត្រូវបានបញ្ចប់ក្នុងអំឡុងពេលនេះ ហើយរដ្ឋសភាជាតិក៏បានអនុម័តច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពីនៃការប្រកួតប្រជែងមិនស្មោះត្រង់និង ច្បាប់ស្តីអំពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលផងដែរ ។ នៅពេលដែលការពិភាក្សាក្នុងក្រុមការងារមានដំណើរចំរើនទៅមុខក្នុងឆ្នាំ២០០៣នោះ យើងអាចវិនិច្ឆ័យបាននូវទំហំនៃកិច្ចខិតប្រឹងប្រែង ផ្ទៃក្នុងដែលនឹងអាចធ្វើអោយកម្ពុជាមានច្បាប់ ដែលមានសង្គតភាពទៅនឹងវិធាននៃអង្គការពាណិជ្ជកម្មពិភពលោកនៅពេលដែលកម្ពុជាបានចូលអង្គការនេះ ហើយយើងត្រូវការ ពេលវេលាបន្ថែមទៀត ដើម្បីរៀបចំនូវច្បាប់ចាំបាច់មួយចំនួនទៀត។

ទី២ ក្នុងប៉ុន្មានថ្ងៃមុន និងបន្ទាប់ពីកិច្ចប្រជុំក្រុមការងារនីមួយៗ យើងបានជួបជាមួយសមាជិកមួយចំនួនដោយផ្ទាល់ ។ កិច្ចប្រជុំទ្វេភាគីនេះ ត្រូវបានកំណត់ឡើងតាមការស្នើសុំរបស់សមាជិកនីមួយៗនិងបានអនុញ្ញាតអោយសមាជិកទាំងនោះដាក់សំណើសុំធ្វើការផ្លាស់ប្តូរឬបន្ថែមទៅលើសម្បទានលើកដំបូង ដែលយើងបានលើកឡើងដូចជា ការចងពន្ធគយ និងការបើកច្រកទីផ្សារសេវាកម្ម ។ សំណើទាំងនេះជាធម្មតាត្រូវបានធ្វើឡើង ដើម្បីសុំបន្ទាបអត្រាពន្ធគយចងចំពោះផលិតផល ដែលជាផលប្រយោជន៍ពាណិជ្ជកម្មរបស់ប្រទេសជាសមាជិក ឬ ស្នើសុំអោយបន្ថែមវិស័យសេវាកម្មណាមួយទៅក្នុងសម្បទានបើកទីផ្សារសេវាកម្មរបស់យើង ។ យើងបានពិនិត្យការស្នើសុំនីមួយៗនិងពិចារណា តើសំណើណាមួយអាចបញ្ចូលនៅក្នុងយុទ្ធសាស្ត្រដែលយើងបានរៀបចំ សំរាប់ការចរចារួចហើយ។

នៅក្នុងអំឡុងពេលនៃដំណើរការចរចាជាសមាជិក កម្ពុជាបានជួបចរចាទ្វេភាគីជាមួយប្រទេសជាសមាជិក ចំនួន ៩ ប្រទេស គឺ (អូស្ត្រាលី កាណាដា សហគមន៍អ៊ឺរ៉ុប ឥណ្ឌា ជប៉ុន សាធារណៈរដ្ឋកូរ៉េ ប៉ាណាម៉ា ចិនតៃវ៉ាន់ និងសហរដ្ឋអាមេរិក) ។ នៅចុងបញ្ចប់នៃដំណើរការនេះរាល់ការផ្លាស់ប្តូរទាំងអស់លើសម្បទានដំបូងរបស់យើង ដែលបានព្រមព្រៀងជាមួយប្រទេសជាសមាជិក ត្រូវបានយកទៅដាក់បញ្ចូលទៅក្នុងតារាងនៃការសន្យាស្តីពីពន្ធគយ និងតារាងនៃ

ការសន្យាបើកទីផ្សារសេវាកម្ម ។ តារាងទាំងពីរនេះ គឺជាផ្នែកមួយនៃពិធីសារចូលជា សមាជិក ហើយក៏ជាផ្នែកមួយ នៃកាតព្វកិច្ចផ្លូវច្បាប់របស់យើង ក្នុងនាមជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ។

ទី៣ ក្នុងសប្តាហ៍នៃកិច្ចប្រជុំក្រុមការងារនីមួយៗ យើងបានជួបជាមួយសមាជិកមួយចំនួនតូច ដែលចង់ស្វែងយល់អំពីកម្មវិធីរបស់កម្ពុជាដែលផ្តល់ប្រយោជន៍ដល់វិស័យកសិកម្ម ។ កិច្ចប្រជុំពហុភាគីពិសេសនេះមានបំណងអនុញ្ញាតអោយសមាជិកនានាយល់បានថា តើកម្មវិធីណានៃកម្មវិធីទាំងនេះអាចប៉ះពាល់ដល់ពាណិជ្ជកម្មអន្តរជាតិ ។ វិធាននៃអង្គការពាណិជ្ជកម្មពិភពលោកមិនបានដាក់កំហិតចំពោះការឧបត្ថម្ភធនជាទូទៅ ដែលរដ្ឋាភិបាលមួយអាចផ្តល់ដល់វិស័យកសិកម្មរបស់ខ្លួន តែវិធានទាំងនោះបានដាក់កំហិតលើការឧបត្ថម្ភធនមានទំរង់ជាក់លាក់មួយចំនួន ដែលការឧបត្ថម្ភធនបែបនោះប៉ះពាល់ដល់ការធ្វើពាណិជ្ជកម្ម ។ ហេតុដូច្នេះវាមានសារៈសំខាន់សំរាប់យើង ក៏ដូចជាសមាជិកនានាត្រូវមានការយល់ដឹងរួមមួយលើកម្មវិធីឧបត្ថម្ភធនរបស់កម្ពុជា ថាតើកម្មវិធីណាមួយ ស្ថិតនៅក្នុងចំណាត់ប្រភេទមិនអនុញ្ញាត ។

**<u>លទ្ធផលៈ</u>**

សមាជិកអង្គការពាណិជ្ជកម្មពិភពលោក បានយល់ព្រមទៅលើលក្ខខ័ណ្ឌនៃការសន្យាធ្វើនានារបស់កម្ពុជា ដែលអនុញ្ញាតឱ្យកម្ពុជាអាចចូលរួមបានក្នុងអង្គការពាណិជ្ជកម្មពិភពលោកនាកិច្ចប្រជុំចុងក្រោយរបស់ក្រុមអ្នកចរចា ក្នុងខែសីហា ឆ្នាំ២០០៣ ។ លក្ខខ័ណ្ឌ និងការសន្យាធ្វើនានា គឺជាលទ្ធផលនៃការចរចា ដែលបានពិពណ៌នាខាងលើ ។ ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបនូវលទ្ធផលសំខាន់ៗនេះ ។

***<u>ពន្ធគយលើទំនិញនាំចូលៈ</u>*** កម្ពុជានឹងចងគ្រប់រាល់ប្រភេទមុខទំនិញជាប់ពន្ធទាំងអស់ (Tariff line) របស់ខ្លួន ។ កំរិតដែលបានព្រមព្រៀងនៃការចងពន្ធ គឺស្មើរធំជាងកំរិតពន្ធគយដែលកម្ពុជាយើងបានអនុវត្តនាឆ្នាំ២០០៣ ។ ដូច្នេះ គ្មានការកាត់បន្ថយពន្ធគយពិតប្រាកដ

ណាមួយ ដែលតំរូវអោយធ្វើដោយសារសមាជិកភាពនៃអង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជាទេ អត្រាពន្ធចងជាមធ្យមជាទូទៅ ដែលយើងបានព្រមព្រៀងគឺ ១៩.៩ភាគរយ ។ បើប្រៀបធៀបជាមួយ អត្រាពន្ធ ដែលបានអនុវត្តក្នុងឆ្នាំ ២០០៣ គឺប្រមាណ ១៦.៥ ភាគរយ ។ អត្រាពន្ធចងលើ ផលិតផលកសិកម្ម គឺ ២៩.៤ភាគរយ បើប្រៀបធៀបជាមួយអត្រាជាមធ្យម ដែលបានអនុវត្ត ក្នុងឆ្នាំ២០០៣ គឺ ១៩.៤ ភាគរយ ។ អត្រាពន្ធចងជាមធ្យមចំពោះផលិតផលឧស្សាហកម្ម គឺ ១៨.៤ ភាគរយ ហើយអត្រាដែលបានអនុវត្តក្នុងឆ្នាំ២០០៣ គឺ ១៦ ភាគរយ ។

***<u>ការនាំចូលសេវាកម្ម:</u>*** កម្ពុជាបានសន្យាបើកទីផ្សារ លើអនុវិស័យសេវាកម្មយ៉ាងហោចណាស់មួយនៅក្រោមវិស័យសេវាកម្មទាំង១១ ។ ផ្នែកទាំងនោះគឺៈ សេវាកម្មអាជីវកម្ម សេវាកម្មទូរគមនាគមន៏ សេវាកម្មសំណង់ និងវិស្វកម្ម សេវាកម្មចែកចាយទំនិញ សេវាកម្មអប់រំ សេវាកម្មបរិស្ថាន សេវាកម្មហិរញ្ញវត្ថុ សេវាកម្មពាក់ព័ន្ធទៅនឹងសុខភាពអនាម័យ សេវាកម្មទេសចរណ៍និងការធ្វើដំណើរ សេវាកម្មកំសាន្តនានា និងសេវាកម្មដឹកជញ្ជូន ។

ការសន្យាដែលយើងបានធ្វើក្នុងផ្នែកសេវាទាំងនេះ គឺមានលក្ខណៈដូចតទៅ :

ទី១: យោងទៅតាមយុទ្ធសាស្រ្តសេវាកម្មរបស់យើង ដែលបានពិពណ៌នាខាងលើយើងបានប្រមូលផ្តុំការចរចារបស់យើងទៅលើវិស័យ ដែលអាចរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងវិស័យសេវាកម្មទាំងនោះ លក្ខណៈតំរូវនៃការធ្វើពាណិជ្ជកម្ម ដែលអាចកែលំអរបរិយាកាសសំរាប់វិនិយោគទុន ។ ឧទាហរណ៍ យើងបានសន្យាអនុញ្ញាតអោយក្រុមហ៊ុនបរទេសធ្វើ

ប្រតិបត្តិការក្នុងវិស័យសេវាកម្មច្បាប់ (មានករណីលើកលែងខ្លះៗ) គណនេយ្យសវនកម្ម ការធ្វើបញ្ជីស្នាម ធនាគារ ការពិគ្រោះយោបល់ផ្នែកគ្រប់គ្រង ទូរគមនាគមន៍ និងដឹកជញ្ជូន ។

ទី២: ក្រៅពីនេះ យើងបានសន្យាបើកទីផ្សារលើវិស័យសេវាកម្ម ដែលជួយជនជាតិកម្ពុជាយើង ក្នុងការបង្កើតជំនាញបច្ចេកទេស ដែលជាតំរូវអោយមានក្នុងសេដ្ឋកិច្ច ដែលមានការប្រកួតប្រជែងខ្ពស់ ។ ដូច្នេះ យើងបានសន្យាអនុញ្ញាតិអោយក្រុមហ៊ុនបរទេសផ្តល់សេវាកម្មឧត្តមសិក្សានិងការអប់រំមនុស្សពេញវ័យ ។

ជាចុងក្រោយ យើងបានសន្យាបើកទីផ្សារលើវិស័យសេវាកម្ម ដែលយើងគិតថាអាចរួមចំណែកលើកកំពស់សុខុមាលភាព និងផ្នែកអនាម័យសាធារណៈ។ យើងជឿជាក់ថា ការធ្វើបែបនេះ អាចរួមចំណែកកែលំអរ សុខភាពសាធារណៈ ក្នុងប្រទេសកម្ពុជា ។

មានការពិចារណាមួយចំនួនទៀត ដែលមានឥទ្ធិពលដល់ការសំរេចចិត្តរបស់យើង លើការយល់ព្រម រឺមិនយល់ព្រមតាមសំណើរបស់ប្រទេសជាសមាជិក ។ ទី១: យើងមានអារម្មណ៍ថាអាចទទួលយកបានការសន្យាបើកទីផ្សារលើវិស័យសេវាកម្ម ដែលយើងមានគោលនយោបាយបើកចំហជាយូរមកហើយ ដែលអនុញ្ញាតអោយបរទេសផ្តល់សេវាកម្មបាន ហើយគោលនយោបាយនេះមានដំណើរការយ៉ាងល្អ ។ ករណីនេះមានដូចជា ធនាគារ ទេសចរណ៍ និងសេវាកម្មបញ្ជូនកញ្ចប់ប្រៃសណីយ៍ ។ យើងមានអារម្មណ៍ទុកចិត្តចំពោះការបើកទីផ្សារលើវិស័យសេវាកម្មមួយចំនួនទៀត ដែលយើងដឹងថា កម្ពុជាអាចប្រកួតប្រជែងបានយ៉ាងជោគជ័យ ជាមួយបរទេស ដូចជាសេវាកម្មមគ្គុទេសទេសចរណ៍ជាដើម ។ ទោះបីយ៉ាងណាក៏ដោយ យើងមើលឃើញផលប្រយោជន៍ នៃការរក្សាទុកផ្នែកខ្លះនៃទីផ្សារសំរាប់សហគ្រាស

ធុនតូច និងធុនមធ្យមរបស់កម្ពុជា ។ ឧទាហរណ៍ យើងសន្យាបើកទីផ្សារសេវាកម្មសណ្ឋាគាររបស់យើងសំរាប់តែការវិនិយោគលើសណ្ឋាគារចាប់ពីថ្នាក់ផ្កាយបីឡើងទៅ ហើយសន្យាបើកទីផ្សារសេវាកម្មលក់រាយចំពោះតែមុខទំនិញមួយចំនួននិងសំរាប់តែហាងទំនិញ ធំៗតែប៉ុណ្ណោះ ។

ជាទូទៅយើងជឿជាក់ថា យើងបានបញ្ចប់ការសន្យាបើកទីផ្សារសេវាកម្មជាមួយការសន្យាមួយចំនួន ដែលឆ្លើយតបយ៉ាងពេញលេញទៅនឹងយុទ្ធសាស្ត្ររបស់យើងនិងដែលរួមចំណែកដល់ការអភិវឌ្ឍន៍របស់ កម្ពុជានៅពេលអនាគត ។

***<u>ការគាំពារចំពោះវិស័យកសិកម្ម:</u>*** តាមការត្រួតពិនិត្យរបស់សមាជិកអង្គការពាណិជ្ជកម្មពិភពលោក លើនយោបាយគាំពារចំពោះវិស័យកសិកម្មរបស់កម្ពុជាបានបញ្ជាក់ថាកម្ពុជាមិនបានផ្តល់ការគាំពារបែបណាមួយ ដែលធ្វើអោយប៉ះពាល់ដល់ការធ្វើពាណិជ្ជកម្មអន្តរជាតិទេ ។ ដូច្នេះកម្ពុជាមិនត្រូវអោយ សន្យាលើការកាត់បន្ថយការគាំពារនោះទេ ។

ស្ថិតក្រោមច្បាប់របស់អង្គការពាណិជ្ជកម្មពិភពលោកបច្ចុប្បន្ន កម្ពុជាមានជំរើសក្នុងការផ្តល់ឧបត្ថម្ភធន ដែលអាចធ្វើអោយប៉ះពាល់ដល់ការធ្វើពាណិជ្ជកម្មទៅតាមការកំណត់ស្មើនឹង ១០ភាគរយ នៃតំលៃទិន្នផលកសិកម្មរបស់ខ្លួន (ក្នុងករណីមានការគាំពារទូទៅ) និង ១០ភាគរយ នៃតំលៃធុញ្ញជាតិមួយមុខៗ (ក្នុងករណីមានការឧបត្ថម្ភធនតែចំពោះប្រភេទធុញ្ញជាតិនីមួយៗ ) ។ ក្រៅពីនេះ កម្ពុជាមានសិទ្ធិផ្តល់នូវការគាំពារគ្មានកាលកំណត់ចំពោះវិស័យកសិកម្មរបស់ខ្លួន តាមវិធីដែលមិនធ្វើអោយប៉ះពាល់ដល់ការធ្វើពាណិជ្ជកម្ម ។ លក្ខខ័ណ្ឌបែបនេះសមល្មមចំពោះគោលនយោបាយគាំពារទាំងឡាយ ដែលរដ្ឋាភិបាលថ្មីចង់អនុវត្ត ។

កម្ពុជាបានធ្វើការសន្យាថា មិនផ្តល់ឧបត្ថម្ភធនចំពោះការនាំចេញផលិតផលកសិកម្មទេ ។ កម្ពុជា មិនបានពិចារណាផ្តល់ការឧបត្ថម្ភធនបែបនេះទេ ហើយរដ្ឋាភិបាលមិនជឿថា ការឧបត្ថម្ភធននេះជាគោលនយោបាយដ៏ល្អឡើយ ។ ជាការពិតលក្ខណៈពិសេសនៃសេដ្ឋកិច្ចកម្ពុជាដែលបន្ថយការប្រកួតប្រជែងរបស់អ្នកនាំចេញផលិតផលកសិកម្មរបស់យើង គឺការចំណាយដឹកជញ្ជូនក្នុងស្រុកខ្ពស់ ដោយសារផ្លូវគមនាគមន៍មិនល្អ និងការចំណាយមិនផ្លូវការផ្សេងៗទៀតក្នុងការដឹកជញ្ជូន ។ ប៉ុន្តែ គោលនយោបាយ និងការខ្សត់ធនធានរបស់កម្ពុជា តំរូវអោយមានការលុបបំបាត់បញ្ហា ដែលបានគូសបញ្ជាក់ខាងលើនេះជាជាងការប្រើប្រាស់នយោបាយឧបត្ថម្ភធនលើការនាំចេញ ដើម្បីទូទាត់ចំណាយអោយអ្នកនាំចេញ ដែលគ្រាន់តែជាមធ្យោបាយបណ្តោះអាសន្នតែប៉ុណ្ណោះ ។

***ភាពស្របគ្នា នៃវិធានពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោកៈ***

ពិធីសារ នៃការចូលជាសមាជិករបស់កម្ពុជាទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក គឺមានឯកសារ យោងចំនួន២៩ ដោយឡែកពីគ្នា ហើយពិធីសារនោះ មានពតិមានលំអិតដែលពិពណ៌នាអំពីវិធីសាស្ត្រដែលកម្ពុជា នឹងអនុវត្តការសន្យារបស់ខ្លួនអោយស្របទៅតាមវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក ។ ដូចដែលបានបញ្ជាក់ជូនខាងលើរដ្ឋាភិបាល និងសភាជាតិ មានការពាក់ព័ន្ធយ៉ាងសំខាន់ក្នុងការរៀបចំ និងអនុម័តច្បាប់ និងបទបញ្ជាទាំងឡាយ ដែលធ្វើអោយកម្ពុជាមានច្បាប់និងបទប្បញ្ញត្តិគ្រប់គ្រាន់ហើយមានសង្គតភាពទៅនឹងនិងវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក ។ ទោះបីជាយ៉ាងណាក៏ដោយនៅពេលចរចាសុំចូលជាសមាជិករបស់យើងបានបញ្ចប់ មិនមែនមានន័យថា ការងាររបស់យើងបានចប់សព្វគ្រប់នោះទេ ហើយសេចក្តីប្រកាសចំនួន ២៩ បានអោយឃើញថា ការកែទំរង់បទប្បញ្ញត្តិក្នុងវិស័យផ្សេងៗ មួយចំនួនកំពុងតែប្រព្រឹត្តទៅ ។ សេចក្តីប្រកាសទាំង ២៩ នោះទាក់ទងទៅនឹងគោលនយោបាយផ្សេងៗ ដែលគ្របដណ្តប់លើវិស័យមួយចំនួនក្រោមកិច្ចព្រមព្រៀងអង្គការ ពាណិជ្ជកម្មពិភពលោក ។ ក្នុងចំណោមវិស័យទាំង ២៩ មានវិស័យចំនួន ១៧ ដែលច្បាប់ និងបទប្បញ្ញត្តិ បច្ចុប្បន្នរបស់កម្ពុជាហាក់ដូចជាមានសង្គតភាពរួចហើយទៅតាម

វិធានរបស់អង្គការពាណិជ្ជកម្មពិភពលោករួចហើយ រឺក៏អាចធ្វើអោយស្របតាមបានដោយសេចក្តីសំរេចរបស់រដ្ឋាភិបាលនៅមុនថ្ងៃចូលជាសមាជិក ។ នៅក្នុងវិស័យទាំងនេះ ការសន្យារបស់កម្ពុជា គឺអនុវត្តតាមវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោកចាប់ពីថ្ងៃបានចូលជាសមាជិក ។ ប្រធានបទទាំងនោះ រួមមានៈ

- គោលនយោបាយកំណត់ថ្លៃ
- ការយកពន្ធគយផ្សេងៗក្រៅពីពន្ធគយធម្មតា
- ការលើកលែងពន្ធ
- ប្រាក់ចំណាយសំរាប់និតិវិធីគយ
- ពន្ធក្នុងស្រុក
- កូតា ការផ្តល់អាជ្ញាប័ណ្ណ និង របាំងមិនមែនពន្ធគយដទៃទៀត (លើកលែងតែថ្នាំសំលាប់សត្វល្អិត និង ជីជំណាំ សូមមើលនៅខាងក្រោម)
- ការត្រួតពិនិត្យទំនិញមុនពេលផ្ទុក
- ការដាក់កំហិតលើការនាំចេញ
- ការឧបត្ថម្ភធនចំពោះឧស្សាហកម្ម
- វិធានការវិនិយោគដែលពាក់ព័ន្ធនឹងពាណិជ្ជកម្ម
- ការធ្វើពាណិជ្ជកម្មរបស់រដ្ឋ
- តំបន់សេដ្ឋកិច្ចសេរី និងតំបន់ពាណិជ្ជកម្មពិសេស
- ពាណិជ្ជកម្ម និងការដឹកជញ្ជូនទំនិញឆ្លងកាត់
- ការឧបត្ថម្ភធនលើការនាំចេញផលិតផលកសិកម្ម
- ពាណិជ្ជកម្មលើផលិតផលវាយនភ័ណ្ឌ
- ការបោះពុម្ពផ្សាយពត៌មានពាណិជ្ជកម្ម
- កិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរី

លក្ខណៈបែបនេះបានធ្វើអោយវិស័យចំនួន ១២ទៀត របស់កម្ពុជានៅមិនទាន់បានធ្វើអោយស្របទៅតាមវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោកនៅឡើយ ឬដែលកម្ពុជាបានសន្យារួចហើយចំពោះគោលនយោបាយ ឬវិធានការនានា តែបច្ចុប្បន្នមិនបានអនុវត្ត ។

វិស័យ៣ ក្នុងចំណោមវិស័យទាំង១២ កម្ពុជាបានធ្វើអោយស្របតាមវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក តាមរយៈការបញ្ជូនច្បាប់ទាំងនោះទៅជូនសភាជាតិដើម្បីធ្វើការអនុម័ត ។ នៅពេលដែល កម្ពុជាបានបញ្ចប់ការចរចាក្នុងខែកក្កដា ឆ្នាំ២០០៣ កម្ពុជាជឿជាក់ថា សភាជាតិអាចអនុម័តសេចក្ដីព្រាងច្បាប់ទាំងនោះបានក្នុងពេលឆាប់ៗ ។ ហេតុដូច្នេះហើយបានជាយើងសន្យាធ្វើអោយក្រមគយរបស់កម្ពុជា ស្របទៅតាមវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោកនៅពាក់កណ្ដាលឆ្នាំ ២០០៤ ហើយនិងសន្យាបង្កើតអោយមានច្បាប់ស្ដីពីតុលាការ ព្រមទាំងបង្កើតប្រព័ន្ធតុលាការពាណិជ្ជកម្ម មួយអោយបានត្រឹមខែមករា ឆ្នាំ ២០០៥ ។ វិបត្តិនយោបាយកន្លងមក បានធ្វើអោយសភាជាតិ មិនអាចកើតចេញជារូបរាងបាន ដែលបណ្ដាលអោយមានការមន្ទិលសង្ស័យទៅលើសមត្ថភាពរបស់កម្ពុជា ក្នុងការឆ្លើយតបតាមកាលបរិច្ឆេទ នៃការអនុវត្តការសន្យារបស់ខ្លួន ។

វិស័យ៤ ផ្សេងទៀត ដែលចាត់ទុកថា ជាវិស័យសំខាន់ចំពោះកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក កម្ពុជាបានធ្វើអោយមានការរីកចំរើនមួយផ្នែកធំក្នុងការធ្វើអោយច្បាប់ និងបទបញ្ញានានារបស់ខ្លួនស្របទៅតាមវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក ។ ដោយសារភាពស្មុគស្មាញនៃបញ្ហានេះ វាជាការពិតណាស់ថា កម្ពុជាមិនអាចបញ្ចប់អោយបានឆាប់នូវសកម្មភាពទាំងឡាយដែលចាំបាច់ ដើម្បីសំរេចបាននូវភាពស្របគ្នាទាំងស្រុងបានទេ ។ ទោះបីយ៉ាងណាក៏ដោយ ក៏សមាជិកអង្គការពាណិជ្ជកម្មពិភពលោកបានព្រមព្រៀងចំពោះសំណើរបស់កម្ពុជាលើ គំរោងផែនការពិសេសសំរាប់ប្រទេសក្រីក្រ ត្រូវតែអនុវត្តចំពោះវិស័យទាំងនោះ ។ នេះមានន័យថា ការចូលជាសមាជិករបស់កម្ពុជាត្រូវតែប្រព្រឹត្តិទៅទោះបីជា កម្ពុជាមិនអាចអនុវត្តវិធានច្បាប់ទាំងនេះភ្លាមៗបាន នៅពេលដែលកម្ពុជាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ឬបន្ទាប់ពីការចូលភ្លាមក៏ដោយ ។

ដូចដែលបានកំណត់ដោយគំរោងផែនការពិសេសសំរាប់ប្រទេសក្រីក្រ កម្ពុជាបានរៀបចំផែនការសកម្មភាព ចំពោះវិស័យនីមួយៗក្នុងចំណោមវិស័យទាំងបួននោះ និងសន្យាអនុវត្តផែនការទាំងនោះ ។ ផែនការសកម្មភាពនោះបញ្ជាក់ពីជំហានជាក់ស្តែងមួយចំនួន ដែលកម្ពុជានឹងត្រូវអនុវត្ត ដើម្បីធ្វើអោយច្បាប់ និងបទប្បញ្ញត្តិ នានារបស់ខ្លួនស្របទាំងស្រុងទៅនឹងវិធានច្បាប់ទាំងនោះ និងបញ្ជាក់ផងដែរ ពីពេលវេលានៃការអនុវត្តវិធានការទាំងនោះ ។ ជាក់ស្តែងនៅពេលកម្ពុជាក្លាយជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក កម្ពុជាមិនត្រូវបានគេទាមទារអោយរៀបចំច្បាប់បញ្ញត្តិស្របគ្នាទាំងស្រុងទៅតាមវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក ស្តីពីការវាយតំលៃពន្ធគយទេ ប៉ុន្តែត្រូវអនុវត្តជាជំហានៗ ដើម្បីធ្វើអោយមានភាពស្របគ្នាទាំងស្រុងនៅត្រឹមថ្ងៃទីថ្ងៃ ០១ ខែមករា ឆ្នាំ ២០០៩ ។ ចំពោះរបាំងបច្ចេកទេសផ្នែកពាណិជ្ជកម្ម (ស្តង់ដារ ផលិតផល និងវិធានបច្ចេកទេស ដែលធានាសុវត្ថិភាពនៃផលិតផល) ភាពស្របគ្នាទាំងស្រុង នឹងត្រូវធ្វើអោយបាននៅត្រឹមថ្ងៃទី ០១ ខែមករា ឆ្នាំ២០០៨ ។ ដូចគ្នានេះដែរ ចំពោះផែនការសកម្មភាពក្នុងការធ្វើអោយមានភាពស្របគ្នាលើវិស័យអនាម័យ និងភូតគាមអនាម័យ (វិធានការការពារសុខភាពមនុស្ស រុក្ខជាតិ និងសត្វ ) ត្រូវធ្វើអោយបាននៅត្រឹម ថ្ងៃទី ០១ ខែមករា ឆ្នាំ២០០៨ ។ ជាចុងក្រោយការសន្យារបស់កម្ពុជា ចំពោះការការពារកម្មសិទ្ធិបញ្ញា តំរូវអោយកម្ពុជាចាត់វិធានការមួយចំនួន ដែលអាចធ្វើអោយមានភាពស្របគ្នាតាមវិធានរបស់អង្គការពាណិជ្ជកម្ម ពិភពលោក នៅត្រឹមថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៧។

នៅពេលដាក់ចេញផែនការសកម្មភាពទាំងនោះ កម្ពុជាបានដាក់បញ្ចូលនូវការវាយតំលៃដ៏ពិស្តារពីជំនួយបច្ចេកទេស ដែលចាំបាច់ដើម្បីអនុវត្តផែនការនេះ ទៅតាមពេលវេលាដែលបានកំណត់ ។ បញ្ហានេះត្រូវបានកត់ត្រាយ៉ាងត្រឹមត្រូវ ដោយសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ដែលបានបង្ហាញនូវបំណងរបស់គេក្នុងការផ្តល់នូវជំនួយបច្ចេកទេសនោះតាមរយៈយន្តការរបស់អង្គការពាណិជ្ជកម្មពិភពលោក ដូចជាមូលនិធិសំរាប់ប្រទេសក្រីក្រ និងតាមរយៈកម្មវិធីជំនួយបច្ចេកទេសទ្វេរភាគី ។

ផែនការសកម្មភាពទាំងនោះនឹងអាចធ្វើអោយច្បាប់ និងបទបញ្ញារបស់កម្ពុជាស្របទៅនឹងវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក បន្ទាប់ពីថ្ងៃចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។ នោះគឺជាសារៈសំខាន់នៃភាពបត់បែនក្នុងដំណើរការចរចាចូលជា សមាជិករបស់កម្ពុជា។ ការបញ្ចូលផែនការទាំងនេះទៅក្នុងការសន្យាធ្វើរបស់កម្ពុជាអាចធ្វើទៅបានដោយសារតែសកម្មភាពការទូត និងសម្ពាធនយោបាយ ដែលកើតមានឡើងនៅទីក្រុងហ្សឺណែវ ដោយក្រុមប្រទេសក្រីក្រដែលបានធ្វើការងារនេះអស់រយៈពេលច្រើនឆ្នាំ ដើម្បីកែទំរង់នីតិវិធីរបស់អង្គការពាណិជ្ជកម្មពិភពលោក ដោយធ្វើការពិចារណាទៅលើការលំបាកជាពិសេស ដែលប្រទេសក្រីក្រទាំងអស់កំពុងជួបប្រទះ ។ ការចូលជាសមាជិករបស់កម្ពុជាទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក នឹងមិនអាចប្រព្រឹត្តទៅបានទេ បើគ្មានការកែទំរង់ទាំងនោះ។

គេត្រូវការជាចាំបាច់នូវអនុសាសន៍ពិសេសមួយចំពោះការសន្យារបស់កម្ពុជាលើការការពារកម្មសិទ្ធិបញ្ញា ។ សំណួរជាច្រើនត្រូវបានចោទឡើងថា តើការសន្យាទាំងនេះអាចធ្វើអោយកម្ពុជាទទួលបានផលប្រយោជន៏ពេញលេញពីសេចក្តីប្រកាសទីក្រុង ដូហា លើកិច្ចព្រមព្រៀង ស្តីពីពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា និង សុខភាពសាធារណៈទេ ។ ដូចដែលបានលើកឡើងខាងលើគោលបំណងសំខាន់របស់កម្ពុជាក្នុងការចរចា គឺការធ្វើអោយប្រាកដថាកម្ពុជា អាចទាញយកផលប្រយោជន៍ពីសេចក្តីប្រកាសនេះ ។

យើងជឿជាក់ថា កម្ពុជាអាចឈានដល់គោលដៅនេះ ។ អ្នកសង្កេតការណ៍ខ្លះបានផ្តល់យោបល់ទៅលើប្រយោគពីរ ដែលមានចែងនៅក្នុងការសន្យាធ្វើរបស់កម្ពុជា ដែលទាក់ទងនិងការប្រើប្រាស់ទិន្នន័យសាកល្បង នៅក្នុងការអនុវត្តន៏ការការពារប្រកាសនីយបត្រ័តក្កកម្ម ។ វាជាការពិតណាស់ថា ប្រយោគទាំងពីរនោះត្រូវបានអានដាច់ដោយឡែកពីប្រយោគដទៃទៀត ហើយបណ្តាលអោយខូចដល់សមត្ថភាពខ្លះរបស់កម្ពុជាក្នុងការទាញយកប្រយោជន៍ពីសេចក្តីប្រកាសទីក្រុង ដូហា នេះ ។ ទោះបីជាយ៉ាងណាក៏ដោយ គួរកត់សំគាល់ផងដែរថា ច្បាប់ស្តីពីប្រកាសនីយបត្រ័កម្មរបស់កម្ពុជាមានបទប្បញ្ញត្តិនានា ដែលអាចអោយកម្ពុជាយើងអាច

អនុវត្តសេចក្តីប្រកាសទីក្រុង ដូហា បានទាំងស្រុង ។ ច្បាប់នេះត្រូវបានផ្តល់ជូន សមាជិកនានារបស់អង្គការពាណិជ្ជកម្មពិភពលោកនៅមុនពេលការបញ្ចប់ការចចារ ហើយគ្មានការអធិប្បាយដោយសមាជិកណាមួយទៅលើបញ្ញត្តិ ដែលទាក់ទងទៅនឹងសេចក្តីប្រកាស ទីក្រុង ដូហា ទេ ។ ជាងនេះទៅទៀត ក្នុងការអញ្ជើញកម្ពុជាអោយចូលជាសមាជិកអង្គការ ពាណិជ្ជកម្មពិភពលោក នៅឯកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី ដែលបានប្រព្រឹត្តទៅនៅទីក្រុង កាន់គូន សមាជិកក្រុមការងារបានប្រកាសថា លក្ខខ័ណ្ឌនៃការចូលជាសមាជិករបស់កម្ពុជានៅពេលនេះមិនបានរារាំងការទទួលប្រយោជន៍របស់កម្ពុជា និង ប្រទេសក្រីក្រនានា ក្រោមសេចក្តីប្រកាសទីក្រុង ដូហា លើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា និង សុខភាពសាធារណៈទេ ។ ហេតុនេះហើយ សមាជិកទាំងអស់បានបញ្ជាក់ពីគោលបំណងយ៉ាងច្បាស់របស់ខ្លួន ហើយកម្ពុជាយល់អំពីប្រយោគទាំងពីរនោះ ព្រមទាំងអនុវត្តវាទៅតាមលក្ខណៈជាក់ស្តែង ។

វិស័យទាំងប្រាំទៀតដែលនៅសល់ ដែលកម្ពុជាបានសន្យាទទួលយក គ្របដណ្តប់លើប្រធានបទជាច្រើន ។ ផ្នែកដែលសំខាន់បំផុត គឺការសន្យាដែលអនុញ្ញាតអោយកម្ពុជាបន្តអនុញ្ញាតអោយការនាំចូលវត្ថុធាតុដើមសំរាប់ប្រើប្រាស់ក្នុងឧស្សាហកម្មនាំចេញរួចផុតពីការបង់ពន្ធនាំចូល ។ ជាការពិតបញ្ហានេះជាបញ្ហាសំខាន់ ចំពោះឧស្សាហកម្មកាត់ដេរសំលៀកបំពាក់នៅកម្ពុជា ដើម្បីធានាថា វត្ថុធាតុដើមនាំចូលត្រូវបង់ថ្លៃទៅតាមតំលៃទីផ្សារអន្តរជាតិ ដែលធ្វើអោយក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់អាចប្រកួតប្រជែងបាននៅលើទីផ្សារពិភពលោក ។

ការទទួលបាននូវសិទ្ធក្នុងការលើកលែងពន្ធនាំចូលវត្ថុធាតុដើមសំរាប់ប្រើប្រាស់ក្នុងឧស្សាហកម្មនាំចេញ ក៏ជាកត្តាសំខាន់មួយដែរ ប្រសិនបើកម្ពុជាអាចទាក់ទាញនូវឧស្សាហកម្មនាំចេញដទៃទៀតបាន ។ ទោះបីជាការលើកលែងពន្ធលើវត្ថុធាតុដើមសំរាប់ឧស្សាកម្មនាំចេញមិនត្រូវបានអនុញ្ញាតដោយវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោកក៏ដោយ ប៉ុន្តែការសន្យារបស់យើងបានអនុញ្ញាតឱ្យកម្ពុជា បន្តអនុវត្តការមិនយកពន្ធលើការនាំចូលលើវត្ថុធាតុដើមសំរាប់ឧស្សាហកម្មនាំចេញរហូតដល់ឆ្នាំ ២០១៣ ។ ការលើកលែងពន្ធនេះបានផ្តល់អោយម្ពុជានូវ

កត្តាសំខាន់ នៃភាពបន់បែនបាននៅក្រោមវិធានធម្មតារបស់អង្គការពាណិជ្ជកម្មពិភពលោក ។ ក្រោយពីឆ្នាំ ២០១៣ កម្ពុជាចាំបាច់ត្រូវជ្រើសយកមធ្យោបាយមួយក្នុងចំណោមមធ្យោបាយផ្សេងៗ ដែលធានាដល់សង្គតភាព ជាមួយនឹងវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក មានន័យថាធានាធ្វើយ៉ាងណាឱ្យ ថាឧស្សាហកម្មនាំចេញរបស់ខ្លួនទទួលបាននូវវត្ថុធាតុដើម ដែលមានតំលៃប្រកួតប្រជែង ។

ជាងនេះទៅទៀត កម្ពុជាបានធ្វើការសន្យាក្នុងការផ្តល់នូវពត៌មានដល់សមាជិកអង្គការពាណិជ្ជកម្មពិភពលោក អំពីកម្មវិធីសេរីភាវូបនីយកម្មរបស់ខ្លួន និង បង្កើតយន្តការមួយ ដែលទទួលភារៈកិច្ចដោះស្រាយបណ្តឹងរវាង ពាណិជ្ជករជាមួយនឹងរដ្ឋាភិបាលអំពីការអនុវត្តរបស់គយ និងអនុញ្ញាតឱ្យក្រុមហ៊ុនដែលបានចុះបញ្ជីទាំងអស់ មានសិទ្ធិនាំចូលនូវផលិតផលឱសថសំរាប់មនុស្ស និង សត្វ ។ ការសន្យាចុងក្រោយទាំងពីរនេះ នឹងចូលជាធរមានក្នុងឆ្នាំ ២០០៥ ។ កម្ពុជាក៏បានសន្យាផងដែរថា នឹងមិនអនុវត្តនូវវិធានការលក់បង្ខូចថ្លៃ វិធានការសុវត្ថិភាព និងវិធានការប្រឆាំងតបត រហូតដល់កម្ពុជាបានអនុម័តច្បាប់ ដែលស្របជាមួយវិធានអង្គការពាណិជ្ជកម្មពិភពលោក សំរាប់ អនុវត្តលើវិធានការទាំងនេះ ។

សរុបមក ការធ្វើច្បាប់កម្ពុជាឱ្យមានសង្គតភាពជាមួយវិធានអង្គការពាណិជ្ជកម្មពិភពលោកបានផ្តល់លទ្ធផលជាវិជ្ជមាន។ ទីមួយ ពីព្រោះការងាររបស់យើងនៅមុន និងក្នុងពេលដំណើរការចរចាចូលជាសមាជិកមួយផ្នែកធំនៃរបបពាណិជ្ជកម្មរបស់កម្ពុជា ត្រូវបានសមាជិកអង្គការពាណិជ្ជកម្មពិភពលោកជាច្រើនវាយតំលៃថា មានភាពស្របគ្នាជាមួយនឹងវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោករួចទៅហើយ ។ ចំពោះវិស័យទាំងឡាយណា ដែលច្បាប់កម្ពុជានៅពុំទាន់ស្របជាមួយនឹងវិធានអង្គការពាណិជ្ជកម្មពិភពលោកនោះ កម្ពុជាត្រូវការពេលវេលាសមស្រប ដើម្បីបំពេញការងារទាំងនោះ ។ជាការពិតហើយការងារទាំងនេះបានបន្សល់ទុកឱ្យយើងនូវភារៈកិច្ចសំខាន់ៗនាពេលអនាគត និងជាប្រធានបទមួយដែលត្រូវពិភាក្សាដូចខាងក្រោម ។

# ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកៈ សមិទ្ធិផល និងការប្រឈម

កម្ពុជា នឹងចូលរួមក្នុងគ្រួសារនៃប្រជាជាតិដែលធ្វើពាណិជ្ជកម្ម នៅក្នុងពិភពលោក ហើយនឹងក្លាយជាសមាជិក ពេញសិទ្ធិរបស់អង្គការពាណិជ្ជកម្មពិភពលោកនាពេលដ៏ខ្លីខាងមុខនេះ ។ ជាងមួយទសវត្សកន្លងមកហើយ ដែលកម្ពុជាបានពង្រឹងទំនាក់ទំនងយ៉ាងជិតស្និតជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងធនាគារពិភពលោក (WB) ហើយបានចូលជាសមាជិកពេញសិទ្ធិរបស់អាស៊ាន ក្នុងឆ្នាំ១៩៩៩ ។ ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក នឹងកត់សំគាល់នូវជំហ៊ានចុងក្រោយនៃការបើកផ្លូវឱ្យកម្ពុជា ចូលរួមក្នុងអង្គការអន្តរជាតិ និងតំបន់សំខាន់ៗ ដែលមានតួនាទីគ្រប់គ្រងទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិ ។

ប៉ុន្តែការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ក៏មានសារៈសំខាន់យ៉ាងច្បាស់លាស់ដែរ ។ សមាជិកភាពរបស់កម្ពុជា នឹងបង្កើតនូវលក្ខខ័ណ្ឌជាក់ស្តែងមួយចំនួនដល់ការធ្វើជំនួញ ដែលកំពុងតែអនុវត្តនៅប្រទេសកម្ពុជាសព្វថ្ងៃនេះ ។ ទី១ និង ចំនុចសំខាន់បំផុត សមាជិកភាពអង្គការពាណិជ្ជកម្មពិភពលោក នឹងជួយការពារឧស្សាហកម្មកាត់ដេរសំលៀកបំពាក់របស់កម្ពុជា ពីការជាប់កូតា ក្នុងឆ្នាំ ២០០៥ និង ឆ្នាំបន្តបន្ទាប់ ។ ជាការពិតក្នុងពេលជាមួយគ្នានេះកម្ពុជាក៏អាចរក្សាបាននូវភាពមានការងារធ្វើបានដែរ ។ ជាទូទៅរាល់គោលដៅចរចាសំខាន់ទាំង៦ ដែលបានរៀបរាប់ខាងលើ ត្រូវបានទទួលជោគជ័យទាំងស្រុង : កម្ពុជាបានចៀសផុតពីកាតព្វកិច្ចបញ្ចុះពន្ធគយ និងរក្សាបាននូវលទ្ធភាពដែលអាចឱ្យអ្នកនាំចេញធ្វើការនាំវត្ថុធាតុដើមចូល ដើម្បីផលិតដោយមិនបាច់បង់ពន្ធ។ កម្ពុជា នឹងអាចធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគទុនដោយធានា អោយបាននូវភាពបើកចំហទៅកាន់ទីផ្សារអន្តរជាតិ ដោយពុំមានឧបសគ្គ ការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធច្បាប់សំរាប់ធ្វើអាជីវកម្ម និងពង្រីកហេដ្ឋារចនាសម្ព័ន្ធសេវាកម្មសំរាប់ការធ្វើអាជីកម្ម ។ កម្ពុជានឹងរក្សានូវសិទ្ធិសំរាប់ធ្វើការកែតំរូវសមល្មមដើម្បីរៀបចំនូវគោលនយោបាយសមស្របសំរាប់គាំទ្រដល់វិស័យកសិកម្ម ហើយកម្ពុជានឹងទាញយកប្រយោជន៍យ៉ាងពេញលេញ ពីសេចក្តីប្រកាសក្រុងដូហា

ស្តីអំពី ទិដ្ឋភាពនៃកម្មសិទ្ធិបញ្ញាទាក់ទងនឹងពាណិជ្ជកម្ម (TRIPS) និងសុខភាពសាធារណៈ ។ ដូច្នេះ កម្ពុជាបានទទួលជោគជ័យក្នុងការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកដ៏មានអត្ថប្រយោជន៍នេះដែលជំរុញ និង ពង្រឹងថែមទៀត នូវយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចបើកចំហទីផ្សារទៅកាន់ពិភពលោកខាងក្រៅរបស់កម្ពុជា ។ នេះគឺជា សមិទ្ធិផលដ៏សំខាន់របស់កម្ពុជា ។

ទោះបីយ៉ាងណាក៏ដោយការទទួលជោគជ័យយ៉ាងពេញលេញនោះ គឺអាស្រ័យលើអ្វីដែលនឹងកើតឡើងនៅពេលក្រោយ ។ ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនឹងបង្កើតនូវលទ្ធភាពថ្មីៗជាច្រើនសំរាប់កម្ពុជា ប៉ុន្តែមិនធានាថា លទ្ធភាពទាំងនេះនឹងត្រូវប្រែក្លាយជាឧត្តមភាពបានទាំងស្រុងបានទេ ។ ដើម្បី ប្រែក្លាយសក្តានុពលនេះឱ្យក្លាយជាការពិតនោះកម្ពុជា នឹងចាំបាច់ត្រូវតែបំពេញការងារឱ្យបានសកម្មជាងនេះ នៅក្នុងបណ្តាខែ និងឆ្នាំខាងមុខ ។

ជាក់ស្តែង ការប្រឈមដំបូងបង្អស់ គឺការបំពេញកាតព្វកិច្ចកែទំរង់រដ្ឋបាល និងច្បាប់ដែលកម្ពុជាបានសន្យា ដែលមានចែងនៅក្នុងពិធីសារនៃការចូលជាសមាជិកភាពអង្គការពាណិជ្ជកម្មពិភពលោក ។ នៅក្នុងសេចក្តីសំរេច ដែលបានអនុម័តកាល ពីខែកុម្ភៈ ឆ្នាំ២០០៤ ទីស្តីការគណៈរដ្ឋមន្ត្រី បានកំណត់នូវកិច្ចការ ៩៨ ដោយឡែកពីគ្នា ដែលមានចែងក្នុងពិធីសារ និងចាំបាច់ត្រូវតែសំរេចឱ្យបានមុនចុងឆ្នាំ ២០០៥ ហើយបានប្រគល់កិច្ចការទាំងនោះ ទៅឱ្យក្រសួង និងស្ថាប័នពាក់ព័ន្ធចំនួន ២០ ដើម្បីទទួលខុសត្រូវក្នុងការបំពេញកិច្ចការទាំងនោះ ។ ទីស្តីការគណៈរដ្ឋមន្ត្រី នឹងធ្វើការតាមដានជាទៀងទាត់នូវភាពជឿនលឿននៃការអនុវត្តន៍កិច្ចការទាំងនោះ ហើយនឹងបន្ថែមកិច្ចការថ្មីទៅក្នុងរបៀបវារៈ ដែលចាំបាច់ត្រូវបំពេញអោយបានចប់សព្វគ្រប់ក្នុងឆ្នាំ ២០០៦ និងឆ្នាំខាងមុខ ។ នៅពេលដែលកិច្ចការទាំងនោះត្រូវបានបញ្ចប់រួចរាល់ហើយ របបពាណិជ្ជកម្មកម្ពុជា នឹងមានសង្គតភាពទាំងស្រុងជាមួយវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក ហើយនៅពេលនោះបរិយាកាស វិប្រព័ន្ធច្បាប់សំរាប់ធ្វើជំនួញរបស់នឹងឈានទៅដល់កំរិតនៃស្តង់ដារអន្តរជាតិ ។ នេះជាផលប្រយោជន៍យ៉ាងសំខាន់នៅក្នុងការចូលជាសមាជិក អង្គការពាណិជ្ជកម្មពិភពលោក ។

ការទទួលខុសត្រូវ ចំពោះការអនុវត្តន៍កិច្ចការមានចែងក្នុងពិធីសារ នៃការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងជាពិសេសចែងក្នុងផែនការសកម្មភាព ដែលត្រូវបំពេញឱ្យបានទាន់ពេលវេលាកំណត់នោះ គឺជាភារៈកិច្ចទាំងស្រុងរបស់កម្ពុជា ។ ក្នុងករណីមានភាពយឺតយ៉ាវចំពោះការផ្តល់សច្ចាប័នលើពិធីសារ នៃការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនោះ មានន័យថា កាលវិភាគនៃការអនុម័តច្បាប់មានលក្ខណៈតឹងតែង ។ ជាងនេះទៅទៀត ជាការពិតកិច្ចការមួយចំនួនអាចត្រូវសំរេចបានតាមកាលកំណត់ លុះត្រាតែជំនួយបច្ចេកទេសសមស្របត្រូវបានផ្តល់ទាន់ពេលពេលវេលា ។ ប្រសិនបើ ដោយសារតែមូលហេតុទាំងនេះបណ្តាលឱ្យមានការខកខានចំពោះការបំពេញកិច្ចការមួយចំនួន មិនបានសំរេចតាមកាលកំណត់នោះ កម្ពុជានឹងជូនពតិមាន ទៅអង្គការពាណិជ្ជកម្មពិភពលោក និង សុំការធ្វើការកែប្រែឡើងវិញនូវកាលវិភាគដែលកម្ពុជាបានសន្យាកន្លងមក ។

ប្រព័ន្ធច្បាប់មួយ ដែលស្របនឹងវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក ដែលមានលក្ខណៈទំនើបសេរី និងប្រសើរសំរាប់ការធ្វើពាណិជ្ជកម្ម នឹងមានប្រសិទ្ធិភាព លុះត្រាតែ គេយកច្បាប់នោះមកប្រតិបត្តិ និង អនុវត្តន៍ ។ ពាក់ព័ន្ធទៅនឹងបញ្ហានេះ យើងទាំងអស់គ្នាទទួលស្គាល់នូវទំហំនៃការប្រឈមជាច្រើនមុខ ដែលកម្ពុជានឹងជួបប្រទះ។ កម្ពុជាកំពុងស្ថិតនៅក្នុងតំណាក់កាលដំបូងបំផុតនៃការអភិវឌ្ឍន៍ប្រព័ន្ធតុលាការមួយ ដែលមានតួនាទីត្រឹមត្រូវតាមក្រិតក្រម ។ កម្ពុជាត្រូវតែជំរុញការងារនេះជាបន្ទាន់ ហើយទន្ទឹមនេះដែរត្រូវធានាថា វិធានការក្រៅប្រព័ន្ធតុលាការផ្សេងៗទៀត ដូចជា ការកាត់ក្តីដោយអាជ្ញាកណ្តាល (មជ្ឈត្តវិនិច្ឆ័យ) ការអនុវត្តន៍វិធានរដ្ឋបាលត្រូវបានអនុវត្ត យ៉ាងពេញទំហឹង ដើម្បីធានាថា ច្បាប់ត្រូវបានគោរព និងអនុវត្ត ។

ចំណុចចុងក្រោយ កម្ពុជាត្រូវតែដោះស្រាយឱ្យបានឆាប់រហ័សនូវកង្វះខាតមួយចំនួននៃតំណើរប្រព្រឹត្តិទៅប្រចាំថ្ងៃរបស់ស្ថាប័នរដ្ឋាភិបាល ។ បណ្តឹងពីសហគមន៍អ្នកជំនួញអំពីនិតិវិធីរដ្ឋាភិបាលដែលអូសបន្លាយពេលវេលា និងការងារជាន់គ្នារវាងស្ថាប័នរដ្ឋាភិបាលចាំបាច់ត្រូវតែធ្វើការពិនិត្យឡើងវិញអោយបានហ្មត់ចត់ និងធ្វើការដោះស្រាយ និង កែតំរូវដើម្បីឆ្លើយតបទៅនឹងបណ្តឹងទាំងនោះ ។ អំពើពុករលួយ ចាំបាច់ត្រូវតែបំបាត់ចោល មិនមែនគ្រាន់តែ

និយាយចោលទេ ។ ជាការពិតណាស់កម្ពុជាត្រូវបំពេញការងារជាក់លាក់ដើម្បីធានាឱ្យមាននូវអភិបាលកិច្ចល្អតាមរយៈពេលការណ៍តម្លាភាព ភាពអាចទស្សន៍ទាយបានគណនេយ្យភាពនិងគោលការណ៍នីតិរដ្ឋនៅក្នុងសកម្មភាពរបស់រដ្ឋាភិបាលគ្រប់បែបយ៉ាង ។ សមាជិកភាពក្នុងអង្គការពាណិជ្ជកម្មពិភពលោកផ្តល់ឱ្យកម្ពុជានូវមូលហេតុដ៏ល្អ មួយទៀតសំរាប់ការធ្វើដំណើរឆ្ពោះទៅមុខឱ្យបានឆាប់រហ័សក្នុងវិស័យនេះដើម្បីជំរុញសកម្មភាពដែលកម្ពុជាកំពុងទទួលខុសត្រូវក្នុងមូលបទមួយនៃគំរោងស្តីពីអភិបាលកិច្ចដែលទទួលការគាំទ្រពីធនាគារពិភពលោក និងក្រុមប្រទេសផ្តល់ជំនួយផ្សេងទៀត ។

សរុបសេចក្តីមកវិធានការជាលក្ខណៈទូទៅទាំងនេះជះឥទ្ធិពលដល់បរិយាកាសពាណិជ្ជកម្មទាំងមូល ដែលធ្វើឱ្យយើងចាំបាច់បង្កើតនូវគោលនយោបាយពាណិជ្ជកម្មមួយចំនួនថែមទៀតនៃវិស័យមួយចំនួន

កម្ពុជាចាំបាច់ត្រូវពង្រីកមូលដ្ឋាននាំចេញរបស់ខ្លួន ។ កម្ពុជាជឿជាក់ថា ការបង្កើតតំបន់សេដ្ឋកិច្ចពិសេសព្រំដែន គឺជាវិធីមួយសំរាប់សំរេចបាននូវគោលបំណងនេះ ។ តំបន់សេដ្ឋកិច្ចទាំងនេះនឹងធ្វើឱ្យកម្ពុជាមានលទ្ធភាពច្រើនក្នុងការទាក់ទាញវិនិយោគិនបរទេស ជាពិសេសវិនិយោគិនណាដែលចាប់អារម្មណ៍នៅក្នុងការទាញយកអត្ថប្រយោជន៍ពីលក្ខខ័ណ្ឌ GSP របស់កម្ពុជា ដោយធានាឱ្យវិនិយោគិនទាំងនោះទទួលបាននូវច្រកចូលទៅកាន់ទីផ្សារអាស៊ានទទួលបាននូវទីផ្សារអាទិភាពដែលកម្ពុជាមាន ឬនឹងមានដូចជាទីផ្សាររបស់ប្រទេស អូស្ត្រាលី ចិន ឥណ្ឌា និង ញ៉ូហ្សេលេន ។ កម្ពុជាត្រូវប្រឹងប្រែងផងដែរ ស្វែងរកនូវកាលានុវត្តន៍ភាព ដើម្បីពង្រីកពាណិជ្ជកម្មខាងត្បូង - ខាងត្បូងក្រៅពីពាណិជ្ជកម្មជាមួយបណ្តាប្រទេសជិតខាងអាស៊ានរបស់យើងទៀត ហើយត្រូវប្រឹងស្វែងរកលទ្ធភាពក្នុងការចូលរួមនៅក្នុងប្រព័ន្ធអនុគ្រោះពន្ធគយពិភពលោក ដែលជំរុញដល់ការធ្វើពាណិជ្ជកម្មនៅក្នុងចំណោមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ។

យើងជឿជាក់ដែរថា កម្ពុជាអាចធានានូវឧត្តមភាពប្រកួតប្រជែងនៅក្នុងទីផ្សារពិភពលោក ដោយធ្វើឱ្យកម្ពុជាក្លាយជាប្រទេសមួយដែលគ្មានការប្រើប្រាស់កំលាំងពលកម្មលើសម៉ោងដោយបង្ខំ និងគ្មានការប្រើប្រាស់កំលាំងពលកម្មកុមារ ។ ដូច្នេះ កម្ពុជាប្រឹងប្រែងបង្កើននូវយន្តការមួយដើម្បីឱ្យមានការមិនទទួលស្គាល់ជាអន្តរជាតិថា កម្ពុជាគោរពលក្ខខ័ណ្ឌការងារល្អនៅលើទំនិញនាំចេញរួមទាំងទំនិញដែលផលិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសរបស់កម្ពុជាផង។ ធ្វើបែបនេះ បានធ្វើឱ្យឧស្សាហកម្មកាត់ដេរសំលៀកបំពាក់របស់កម្ពុជាមានការទាក់ទាញយ៉ាងខ្លាំងអំពីសំណាក់អតិថិជនដែលចូលចិត្តទិញផលិតផលដែលមានលក្ខណៈត្រឹមត្រូវ និងគោរពតាមស្តង់ដាពលកម្ម អន្តរជាតិ ។ កម្ពុជាចាំបាច់ត្រូវធ្វើដំណើរឱ្យបានឆាប់ដើម្បីផ្តល់នូវអត្ថប្រយោជន៍បែបនេះដល់វិស័យឧស្សាហកម្មកាត់ដេររបស់ខ្លួននៅក្នុងឆ្នាំ ២០០៥ និងឆ្នាំជាបន្តបន្ទាប់ ។ ការធ្វើពាណិជ្ជកម្មជាលក្ខណៈអន្តរជាតិលើវិស័យកាត់ដេរ នឹងមានលក្ខណៈកាន់តែប្រកួតប្រជែងថែមទៀតនៅបន្ទាប់ពីឆ្នាំ ២០០៥ ហើយវាជាតួនាទីរបស់កម្ពុជាក្នុងការផ្តល់អោយឧស្សាហកម្មរបស់ខ្លួននូវមធ្យោបាយស្របច្បាប់គ្រប់បែបយ៉ាងក្នុងការសំរបខ្លួនឱ្យបានជោគជ័យលើការប្រែប្រួលនៃការធ្វើពាណិជ្ជកម្មអន្តរជាតិនាពេលខាងមុខ ។

ការបន្តអនុវត្តយ៉ាងសកម្មនូវភារៈកិច្ចជាច្រើន ដូចបានលើកឡើងខាងលើនឹងធ្វើឱ្យប្រសើរឡើងនូវភាពប្រកួតប្រជែងនៃសគ្រាសរបស់កម្ពុជា និង បង្កើតនូវបរិយាកាសមួយ ដែលមានការទាក់ទាញជាងមុនដល់វិនិយោគិនថ្មីនៅកម្ពុជា ។ អង្គការពាណិជ្ជកម្មពិភពលោកផ្តល់នូវក្របខ័ណ្ឌមួយដែលទទួលស្គាល់ជាអន្តរជាតិ ដែលកម្ពុជាអាចរៀបចំ និងធ្វើការអភិវឌ្ឍន៍រចនាសម្ព័ន្ធស្ថានប័ន និងច្បាប់ និងបន្តអនុវត្តនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចបើកចំហរបស់ខ្លួន ។ ប្រសិនបើកម្ពុជា យកឈ្នះបានការប្រឈមនេះ ហើយយើងពិតជាឈ្នះ នោះការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជា នឹងត្រូវបានអ្នកប្រវត្តិសាស្ត្រជំនាន់ក្រោយចាត់ទុកថាជា ចំណុចរបត់មួយដ៏សំខាន់ ដែលជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅកម្ពុជា ។

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំសូមសំដែងនូវអំណរអរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចំពោះភាពដឹកនាំដ៏ឈ្លាសវៃរបស់សម្តេច ក្នុងការនាំយកព្រះរាជាណាចក្រកម្ពុជាចូលទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក និងការទុកចិត្តរបស់សម្តេចប្រគល់កាតព្វកិច្ចដឹកនាំការចរចាដល់រូបខ្ញុំ ។

ខ្ញុំសូមថ្លែងអំណរគុណដល់អនុប្រធានដ៏មានសមត្ថភាពរបស់ខ្ញុំគឺ ឯកឧត្តម **សុក ស៊ីផាន់ណា** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ឯកឧត្តម **សុខ ចិន្តា សុភា** អគ្គលេខាធិការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង ឯកឧត្តម ឯកអគ្គរដ្ឋទូត **សួស សុមេធ** ចំពោះស្មារតីលះបង់របស់ខ្លួនក្នុងការរៀបចំ និងការចរចាចូលក្នុងអង្គការពាណិជ្ជកម្មពិភពលោក ។

ខ្ញុំសូមថ្លែងអំណរគុណដល់ទីភ្នាក់ងារអន្តរជាតិជាច្រើនចំពោះការដឹកនាំរបស់ពួកគេ ។ ប្រសិនបើគ្មានការជួយគាំទ្រពីទីភ្នាក់ងារទាំងនោះទេ យើងមិនអាចកត់ត្រានូវពេលវេលាជាប្រវត្តិសាស្ត្រនេះបានទេ ។ ភាគី បរទេសទាំងនោះរួមមាន បណ្ឌិត **Supachai Panitchpakdi** អគ្គនាយកនៃអង្គការពាណិជ្ជកម្មពិភពលោក លោក **Mike Moore** អតីតអគ្គនាយកអង្គការពាណិជ្ជកម្មពិភពលោក ឯកឧត្តម ឯកអគ្គរដ្ឋទូត **Andrea Meloni** ប្រធានក្រុមអ្នកចរចាកម្ពុជា អគ្គលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក ជាពិសេសលោក **Ariff Hussein** លោក **Renzo Franco** និងលោក **Cato Adrian** បណ្ឌិត **Rubens Ricupero** អគ្គលេខាធិការនៃសន្និសិទរបស់អង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍន៍ (UNCTAD) លោក **Denis Beslile** នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC) និង បណ្ឌិត **Esperanza Duran** នាយកប្រតិបត្តិនៃអង្គការ AITIC ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់លោក **Mark Malloch Brown** មន្ត្រីគ្រប់គ្រងនៃកម្មវិធីអភិវឌ្ឍន៍របស់អង្គការ

សហប្រជាជាតិ (UNDP) បណ្ឌិត **Kim Hak-Su** លេខាប្រតិបត្តិនៃគណៈកម្មការសង្គម និង សេដ្ឋកិច្ចអាស៊ីប៉ាស៊ីហ្វិក (ESCAP) និង លោក **Carlos A. Magarinos** អគ្គនាយកអង្គការអភិវឌ្ឍន៍ ឧស្សាហកម្មអង្គការសហប្រជាជាតិ (UNIDO) ។

សូមថ្លែងអំណរគុណដល់ ឯកឧត្តម ឯកអគ្គរដ្ឋទូតជាច្រើនប្រចាំនៅទីក្រុងហ្សឺណែវ ដែលបានជួយដល់ក្រុម អ្នកចរចាររបស់យើងជាអាទិ៍ ឯកឧត្តម **M. Supperamanian** ឯកអគ្គរដ្ឋទូតម៉ាឡេស៊ី លោកជំទាវ Puangrad Asavapisit ឯកអគ្គរាជទូត ថៃឡង់ដ៏ និងឯកឧត្តម ឯកអគ្គរដ្ឋទូតអាស៊ានទាំងអស់ ឯកឧត្តម **Henrik Ree Iversen** ឯកអគ្គរដ្ឋទូតដាណឺម៉ាក និងជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃក្របខ័ណ្ឌសមាហរណកម្មសេដ្ឋកិច្ច និង ឯកឧត្តម **Toufiq Ali** ឯកអគ្គរដ្ឋទូតប្រទេសបង់ក្លាដែស ។

ចំណេះដឹងនិងជំនាញ ដែលបានទទួលតាមរយៈជំនួយបច្ចេកទេសនៃក្រុមជំនាញការរបស់ UNCTAD បានផ្តល់លទ្ធភាពដល់យើងឱ្យទទួលបាននូវលទ្ធផលដ៏ឆាប់រហ័សក្នុងការចរចា។ ការណែនាំរបស់ក្រុមជំនាញការនេះជួយយើងឱ្យឆ្លងកាត់មហាសាគរ រហូតបានដល់ផែសុវត្ថិភាព ។ សូមថ្លែងអំណរគុណដល់ក្រុមជំនាញការនេះ ជាពិសេសលោក **Victor Ognivtsev** លោក **Roger Lawrence** លោកស្រី **Jolita Butkeviciene** លោកស្រី **Eila Jonela** និងលោកស្រី **Miho Shirotori** ។

សូមថ្លែងអំណរគុណដល់ទីភ្នាក់ងារស្នូលធ្វើសមាហរណកម្មក្របខ័ណ្ឌសេដ្ឋកិច្ច ដែលទាក់ទងបច្ចេកទេស ពាណិជ្ជកម្មដល់ប្រទេសមានការអភិវឌ្ឍន៍តិចតួច ជាពិសេស លោក **Joseph Smadja** លោក **Hendrik G. Roelofsen** និងលោក **Francesco Geoffroy** មកពី ITC លោក **Chiedu Osakwe** លោកស្រី **Maika Oshikawa** និង លោក

**Raymond Krommenacker** មកពីអង្គការពាណិជ្ជកម្មពិភពលោក លោក **Ataman Aksoy** និង លោក **Su Yong Song** មកពី ធនាគារពិភពលោក លោក **Patrice Chiyota** និង **Georges Chapelier** មកពី UNDP និងក្រុមការងារ UNDP នៅកម្ពុជា ជាពិសេស លោកស្រី Dominique Ait Ouyahia McAdams, Ladislaus Byenkya-Abwooli, Ingrid Cyimana, Sari Laaksonen និង Richard Schiere និង លោក **Marcel Manfua** នៃក្រុម UNCTAD លោក **Sandy Cuthbertson** ប្រធានក្រុម DTIS **លោក Ravi Ranatyake** និងលោកស្រី **Tiziana Bonapace** មកពី UNESCAP ។

សូមថ្លែងអំណរគុណផងដែរដល់ ឯកឧត្តម **Krirk-Krai Jirapaet** មកពីប្រទេសថៃឡង់ដ៍ លោក **John Burley** លោក **Alphaize Xavier** លោក **Sven Callebaut** និងលោក **Stefano Inama** មកពី UNCTAD លោកស្រី **Susan Prowse** មកពី DFID លោក **Richard Carry** និងលោកស្រី **Ebba Dohl** មានមកពី OECD និងលោក **Tan Song Chuan** មកពី **ITIS** ។

ជាចុងក្រោយ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមការងារកម្ពុជា ដែលបានជួយជាមូលដ្ឋានសំរាប់រៀបចំ និង ចរចាសុំចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ហើយប្រសិនបើគ្មានក្រុមការងារនោះទេ យើងមិនអាចចូលខ្លួនចរចាដោយខ្លួនយើងបានឡើយ ។

**ទីស្តីការគណៈរដ្ឋមន្ត្រី**

- ឯកឧត្តម ប៊ុន អ៊ុយ
- ឯកឧត្តម សេង លីមនៅ
- បណ្ឌិត ជា វ៉ាន់ដេត
- លោក ចាប សុថារិទ្ធិ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- ឯកឧត្តម ច័ន្ទ តុងអ៊ីវ
- ឯកឧត្តម គុំ សារ៉ូន
- លោក ទូត សារ៉ាវុធ
- លោក សេន សុវណ្ណ
- លោក ប៉ែន វុធ

**ក្រសួងពាណិជ្ជកម្ម**

- ឯកឧត្តម ម៉ៅ ថូរ៉ា
- លោក ពេជ ឫទ្ធី
- លោក សុខ សុភ័ក្រ្ត
- លោក តឹករ៉េត សំរេច
- លោក វ៉ា វុត្ថសាន
- លោក ប៉ែន សុវិជាតិ
- លោក ក្រៃ សុនហៀង
- លោក ទិត វិទ្ធិពល
- លោក K. B. Thuraisingham

**ក្រសួងធម្មការ និង កិច្ចការសាសនា**

- ឯកឧត្តម ឆន អៀម
- ឯកឧត្តម សៅ វ៉ន
- លោក ងួន វណ្ណចាន់ធី
- លោក អួង សុភារិន

## ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- ឯកឧត្តម ជុច ភឿន
- ឯកឧត្តម ស៊ីម សារ៉ាក់
- លោក ឃួន ចំរើន
- លោក លឹម យូស្វ

## ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ឯកឧត្តម គង់ វិបុល
- ឯកឧត្តម សូរ វិចច័រ
- លោក គុណ ញឹម
- លោក អ៊ុំ សីហា
- លោក អ៊ុយ សម្បត្តិ
- លោក តឹម សុភ័ក្រ

## ក្រសួងអប់រំ យុវជន និងកីឡា

- ឯកឧត្តម ប៉ុក ថន
- លោក សំ សេរីរ័ត្ន

## ក្រសួងបរិស្ថាន

- ឯកឧត្តម ចាន់ សាផាន
- ឯកឧត្តម ខៀវ មុត
- លោក ហេង ណារ៉េត

**ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ**

- ឯកឧត្តម អ៊ុច គឹមអន
- ឯកឧត្តម សួស សុមេត
- លោក ទុយ រី
- លោកស្រី ទូត បញ្ញា
- លោក កែ វិសិដ្ឋ
- លោក ណៃ ម៉េងអ៊ាង

**ក្រសួងសុខាភិបាល**

- ឯកឧត្តម អ៊ឹង ភីរុណ
- លោក ជូ យិន ស៊ីម
- លោក ហេង ហួត
- លោក ច្រឹង សុខន
- លោកស្រី នេត្រ នី

**ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

- ឯកឧត្តម ហ៊ុល លីម
- លោក សាត សាមុត
- លោក ពីង ស៊ីវឡាយ

**ក្រសួងព័ត៌មាន**

- ឯកឧត្តម ស មុនដុង
- លោក ស៊ូ នី

**ក្រសួងមហាផ្ទៃ**

- ឯកឧត្តម ខូវ ម៉េងហ៊ាន
- ឯកឧត្តម សាក់ សេដ្ឋា
- ឯកឧត្តម ឧត្តមសេនីយ៍ត្រី សៅ រ៉ានី
- លោក កែវ វណ្ណថន

**ក្រសួងយុត្តិធម៌**

- ឯកឧត្តម អង្គ វង្ស វឌ្ឍានា
- លោក យូ អុតារា
- លោក ផូវ សំភី

**ក្រសួងការពារជាតិ**

- ឯកឧត្តម ឡាយ អ៊ីពិសិដ្ឋ
- ឯកឧត្តម ឧត្តមសេនីយ៍ទោ ម៉ម សុផាត
- ឯកឧត្តម ឧត្តមសេនីយ៍ទោ វេង ប៊ុនឡាយ
- ឯកឧត្តម ឧត្តមសេនីយ៍ត្រី រស់ សាផន

**ក្រសួងសាធារណការ និង ដឹកជញ្ជូន**

- ឯកឧត្តម តាន់ ស៊ិនតូ
- លោក ជាម សុវណ្ណនី
- លោក ស្រី សិរីវឌ្ឍន៍
- លោក សុខុម វីរៈពល
- លោក អៀង វេងស៊ិន

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- ឯកឧត្តម ម៉ម សុផាណា
- លោក ហ៊ុយ ណាវ៉ា
- លោក សូ វណ្ណា

**ក្រសួងផែនការ**

- ឯកឧត្តម សារ៉ាក់ ខាន់
- លោក ទូន ថាវរៈ
- លោក សួន សុខឃីម
- លោក ហួយ សិទ្ធិគុណ

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

- ឯកឧត្តម កួយ គីមស៊ា
- កញ្ញា ឡៅ ម៉ាយគៀង
- លោក ហ៊ុល គុណវុឌ្ឍ

**ក្រសួងធនធានទឹកនិងឧតុនិយម**

- ឯកឧត្តម ឃី យុនហេង
- ឯកឧត្តម ទី ឈុន
- លោក ថៃ ចាន់រិទ្ធ

## ក្រសួងអភិវឌ្ឍន៍ជនបទ

- ឯកឧត្តម សួស គង់
- លោក ផាន់ សោភ័ណ្ឌ
- លោក ឆ វេងហួរ
- លោក សៅ ជីវិន្ត
- លោក ឡុច រៀមដែត

## ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- ឯកឧត្តម សាយ ស៊ីផុន
- ឯកឧត្តម អ៊ុំ មាន
- លោក កែវ បុរេន្ទ្រ
- លោក ហួត ចាន់ធី

## ក្រសួងទេសចរណ៍

- ព្រះអង្គម្ចាស់ក្សត្រី ស៊ីសុវត្ថិ ជីវិន្តណារិទ្ធ
- លោក អ៊ិន ធឿន
- លោក ឃិន ណាត

## ក្រសួងធនធានទឹក និងឧតុនិយម

- ឯកឧត្តម វេង សុខុន
- លោក ថេង តារា
- លោក វិន ប៊ុនពៅ

**ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន**

- លោកជំទាវ អ៊ឹង កន្ថាផាវី
- លោកជំទាវ កើត សំអាត
- លោកស្រី ប៊ុនជិត វាសនា

**រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

- ឯកឧត្តម ជុំ អឹក
- លោក នូ សុវណ្ណា
- លោក ខៀវ ចាន់ប៊ុនធឿន

**រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**

- ឯកឧត្តម កែវ សុផល
- លោក ស៊ិន ចាន់សេរីវុត្ថា
- លោក អ៊ុន វិសាលភាព

**ធនាគារជាតិនៃកម្ពុជា**

- ឯកឧត្តម អេង ថៃសាន
- លោកជំទាវ តាល់ ណៃអ៊ីម
- លោកស្រី ងួន សុខា
- លោកស្រី ស្រី ស៊ីយុទ្ធ

**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

- ឯកឧត្តម សុខ ចិន្តា សុភា
- ឯកឧត្តម ឈៀង យ៉ាណារ៉ា
- ឯកឧត្តម សួន សិទ្ធី
- លោក អាន សុផាន់ណារ៉ា
- លោក ជា វុទ្ធី
- លោកស្រី ផេង សុភាព

**គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

- លោក ហែម ហួណារិទ្ធ
- លោក នូ ទេពីរិទ្ធ

# Cambodia WTO Negotiating Team in Geneva













Events in Cancun, Mexico, 11-12 September 2003


Canada Trade Minister


USTR


EU Trade Commissioner



## Events in Cancun Mexico, September 11-12, 2003


Malaysia Ambassador


Amb. Meloni, Chairman of Cambodia Working Party







Scenes of Cambodia Working Party Meetings in Geneva














Sr. Minister and Commerce Minister Cham Prasidh, Cambodian Ambassador Suos Someth and WTO DG Dr. Supachai Panitpakdi (top) and Former WTO DG Mr. Mike Moore (Bottom)









**Lobbying activities and consultations in Geneva**



Sr. Minister and Commerce Minister Cham Prasidh, Cambodian Ambassador Suos Someth and WTO DG Dr. Supachai Panitpakdi (top) and Former WTO DG Mr. Mike Moore (Bottom)






Signing of bilateral agreement with Japan



Signing of bilateral agreement with Korea



Signing of bilateral agreement with the European Commision


Signing of bilateral agreement with Panama


Signing of bilateral agreement with Panama



Signing of bilateral agreement with India

Signing of bilateral agreement with Canada





Conclusion of bilateral agreement with US



Signing of bilateral agreement with Australia

Signing of bilateral agreement with Separate Customs Territory of Taiwan, Penghu, Kinmen and Matsu




Conclusion of bilateral agreement with EC





Negotiations with Korea



Negotiations with Separate Customs Territory of Taiwan, Penghu, Kinmen and Matsu



Negotiations with India

Plurilateral meetings on Agriculture







Negotiations with Panama







Sr. Minister and Commerce Minister Cham Prasidh and Cambodian negotiating team with UNCTAD Sec. Gen. Dr. Rubens Ricupero (top and left), and UNCTAD advisors (bottom)











Preparing for negotiations....







Intensive preparations for negotiation by the Cambodian WTO Think Tank.










High level diplomacy
nd a few moments of
respite....










Moments to remember....


Cheers...





# សេចក្តីកែតំរូវ

នៅទំព័រទី ២ នៃអត្ថបទជាភាសាខ្មែរ សូមបន្ថែមឃ្លាដូចតទៅ "មុនពេលធ្វើការចាប់អារម្មណ៍លើសំណួរដ៏សំខាន់ទាំងនេះ សូមអនុញ្ញាតឱ្យខ្ញុំបាទបកស្រាយឱ្យបានពិស្តារពីមុខងាររបស់អង្គការពាណិជ្ជកម្មពិភពលោក និង ដំណើរការសុំចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក របស់ប្រទេសពុំទាន់ជាសមាជិក"។

នៅទំព័រទី ៤ នៃអត្ថបទជាភាសាអង់គ្លេស ត្រង់បន្ទាត់ទីមួយ កថាខ័ណ្ឌចុងក្រោយដែលសរសេរថា "មានចែង ក្នុងកិច្ចព្រមព្រៀងជាផ្លូវការចំនួន ២៥" សូមកែទៅជា "មានចែងក្នុងកិច្ចព្រមព្រៀងជាផ្លូវការចំនួន ១៨"។

នៅទំព័រទី ៨ នៃអត្ថបទជាភាសាអង់គ្លេស ត្រង់បន្ទាត់ទីពីរ កថាខ័ណ្ឌទីមួយ ពាក្យ "ផ្គត់ផ្គង់" សូមកែទៅជា "អ្នកផ្គត់ផ្គង់"។

នៅទំព័រទី ១៤ នៃអត្ថបទជាភាសាអង់គ្លេស ត្រង់បន្ទាត់ទីប្រាំ កថាខ័ណ្ឌទីមួយ លេខ "១.៣ កោដិដុល្លារ" សូមកែទៅជា "១.៥ កោដិដុល្លារ"។

នៅទំព័រទី ៣០ នៃអត្ថបទជាភាសាអង់គ្លេស ត្រង់បន្ទាត់ទីពីរ កថាខ័ណ្ឌទីពីរ ប្រយោគ "អនុស្សារណៈនៃរបប ពាណិជ្ជកម្ម" សូមកែទៅជា "អនុស្សារណៈនៃរបបពាណិជ្ជកម្មក្រៅប្រទេស"។

នៅទំព័រទី ៣៤ នៃអត្ថបទជាភាសាអង់គ្លេស ត្រង់បន្ទាត់ទីពីរ កថាខ័ណ្ឌទីពីរ ប្រយោគ "អនុស្សារណៈនៃរបប ពាណិជ្ជកម្ម" សូមកែទៅជា "អនុស្សារណៈនៃរបបពាណិជ្ជកម្មក្រៅប្រទេស"។

នៅទំព័រទី ៣៦ នៃអត្ថបទជាភាសាអង់គ្លេស ត្រង់បន្ទាត់ទីពីរ កថាខ័ណ្ឌទីពីរ ប្រយោគ "អនុស្សារណៈនៃរបប ពាណិជ្ជកម្ម" សូមកែទៅជា "អនុស្សារណៈនៃរបបពាណិជ្ជកម្មក្រៅប្រទេស" ។

នៅទំព័រទី ៤២ នៃអត្ថបទជាភាសាអង់គ្លេស ត្រង់បន្ទាត់ទីពីរ កថាខ័ណ្ឌចុងក្រោយ ឃ្លា "ប្រទេសដែលជា សមាជិកចំនួន ៩ (អូស្ត្រាលី កាណាដា សហគមអឺរ៉ុប ឥណ្ឌា ជប៉ុន សាធារណរដ្ឋកូរ៉េ ប៉ាណាម៉ា ចិនតៃប៉ិ និងសហរដ្ឋ អាមេរិក)" សូមកែទៅជា "សមាជិកអង្គការពាណិជ្ជកម្មពិភពលោកចំនួន ៩" ។

នៅទំព័រទី ៤៩ នៃអត្ថបទជាភាសាខ្មែរ សូមបន្ថែមឃ្លាដូចតទៅ "ទោះជាយ៉ាងណាក៏ដោយត្រូវតែដាក់លក្ខខណ្ឌសំខាន់ចំពោះការចូលទៅកាន់ទីផ្សារក្នុងវិស័យដូចជា ហិរញ្ញវត្ថុ (ធនាគារ និងការធានារ៉ាប់រង) និងក្នុងវិស័យ ទូរគមនាគមន៍។ លក្ខខណ្ឌទាំងនេះនឹងធ្វើឱ្យយើងងាយស្រួលតាមដែលយើងចង់បាន ដើម្បីអភិវឌ្ឍន៍គោលនយោបាយបន្ថែមទៀត និងជំរុញការអភិវឌ្ឍន៍ទីផ្សារ" ។

នៅទំព័រទី ៤៩ នៃអត្ថបទជាភាសាខ្មែរ សូមបន្ថែមឃ្លាដូចតទៅ "ទោះជាយ៉ាងណាក៏ដោយវាមានសារសំខាន់ណាស់ដែលការសន្យាផ្តល់ទាំងនេះ គួរតែជួយគាំទ្រដោយការជំរុញគោលនយោបាយ និងច្បាប់ក្នុងវិស័យសេវាកម្ម នីមួយៗ ដោយផ្តោតការយកចិត្តទុកដាក់លើការកំណត់ស្តង់ដាការធានាគុណភាពសេវាដែលបានផ្តល់ និងការជំរុញ ការប្រកួតប្រជែង" ។

នៅទំព័រទី ៥២ នៃអត្ថបទជាភាសាអង់គ្លេស ត្រង់បន្ទាត់ទីបី កថាខ័ណ្ឌទីមួយ ឃ្លា "វាគួរតែជា គោលនយោបាយដ៏ល្អ" សូមកែទៅជា "វាគួរតែជាគោលនយោបាយដ៏ល្អមួយ" ។

នៅទំព័រទី ៥២ នៃអត្ថបទជាភាសាអង់គ្លេស ត្រង់បន្ទាត់ទីមួយ ទីពីរ និងទីបី កថាខ័ណ្ឌទីពីរ សូមចុះមួយបន្ទាត់ ត្រង់ចន្លោះបន្ទាត់ទីពីរ និង ទីបី ។